# ក្រសួងអប់រំ យុវជន និងកីឡា
## Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និង ការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋម សិក្សាក្នុងរាជធានីភ្នំពេញ

# RELATIONSHIP BETWEEN PRINCIPALS' LEADERSHIP AND PUPILS' ENROLLMENT AT PRIMARY EDUCATION IN PHNOM PENH CITY


ជា ច័ន្ទសុភ័ក្ត្រ

Chea Chansopheak


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ

# RELATIONSHIP BETWEEN PRINCIPALS' LEADERSHIP AND PUPILS' ENROLLMENT AT PRIMARY EDUCATION IN PHNOM PENH CITY

ជា ច័ន្ទសុភ័ក្ត្រ

Chea Chansopheak

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២២

គ្រូណែនាំគោល ៖ លោក ម៉ន មុនិន្ទ

គ្រូណែនាំរង ៖ បណ្ឌិត ឈាង សទ្ធាត

# សេចក្តីបញ្ជាក់របស់បេក្ខជន

នាងខ្ញុំសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះមិនទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ សាកលវិទ្យាល័យ ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះ ពិតជាបានត្រូវស្រាវជ្រាវ និងចងក្រងដោយនាងខ្ញុំពិតប្រាកដមែន។

ថ្ងៃ.អាទិត្យ ១៣កើត ខែកត្តិក ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញថ្ងៃទី....០៦.....ខែ.វិច្ឆិកា. ឆ្នាំ២០២២

**ហត្ថលេខា**

**ជា ច័ន្ទសុគ៌ន្ធា**

# សេចក្តីបញ្ជាក់របស់គ្រូណែនាំ

ឈ្មោះ **ម៉ន មុនិន្ទ** ជាគ្រូណែនាំគោល

ឈ្មោះ **ឈាង សទ្ធាត** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

អ្នកស្រី ជា ច័ន្ទសុភ័ក្រ្ត ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៃវិទ្យាស្ថានជាតិអប់រំ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ **«ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ»** ពិតប្រាកដមែន ។

ថ្ងៃ សុក្រ ១១ កើត ខែ កត្តិក ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០២២

**លោក ម៉ន មុនិន្ទ**
ជាគ្រូណែនាំគោល

**បណ្ឌិត ឈាង សទ្ធាត**
ជាគ្រូណែនាំរង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៣៧០២៤ **អយក.ខ៩ន**

**(ការសម្ងាត់)**

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ឧទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ឧទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ឧទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | លាង សេងហាក់ | ឧទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈុក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ វ៉ាំ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អ៊ែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី វង្ខា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំជា ច័ន្ទសុភ័ក្រ្ត ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ឆ្នាំសិក្សា ២០២០ - ២០២២ នៅវិទ្យាស្ថានជាតិអប់រំ ពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែង ដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ដោយជោគជ័យជាស្ថាពរ។ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងធំបំផុតដល់ក្រុមគ្រួសារ បងប្អូនរបស់នាងខ្ញុំ ពួកគាត់បានផ្តល់ កម្លាំងចិត្ត ជំរុញ លើទឹកចិត្តនាងខ្ញុំឱ្យខិតខំតស៊ូប្រឹងប្រែងសិក្សារៀនសូត្រ រហូតទទួលបានជោគជ័យ។

ការបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជាគុណបំណាច់ដ៏ធំធេង របស់លោក **ម៉ន មុនិន្ទ** ជាគ្រូណែនាំគោល និង បណ្ឌិត **ឈាង សទ្ធារ៉ា** ជាគ្រូណែនាំរង ដែលបានជួយពន្យល់ណែនាំ បង្ហាត់បង្ហាញផ្លូវ និង ផ្តល់ជាធាតុចូលយ៉ាងសំខាន់ ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទរបស់នាងខ្ញុំ។ បន្ថែមពីនេះ ពួកគាត់បានផ្តល់ឯកសារ កំណែអក្ខរាវិរុទ្ធ ពាក្យពេចន៍ ឃ្លាឃ្លោង វិធីសាស្ត្រស្រាវជ្រាវ និង របៀបរៀបរៀងនិក្ខេបបទ ឱ្យទទួលបានជោគជ័យជាស្ថាពរ។

នាងខ្ញុំក៏សូមគោរពអរគុណដល់សាស្ត្រាចារ្យ នៅវិទ្យាស្ថានជាតិអប់រំទាំងអស់ ដែលបានខិតខំប្រឹងប្រែង អស់ពីកម្លាំងកាយ កម្លាំងចិត្ត មិនគិតពីការនឿយហត់ រិះរកវិធីសាស្ត្របង្រៀនល្អៗ មកបង្រៀន។ ទោះបីជាពួកគាត់បង្រៀនតាម Online ពិតមែន ប៉ុន្តែពួកគាត់បង្រៀនប្រកបដោយ ឆន្ទៈ មនសិការ យកចិត្តទុកដាក់ និងមានទឹកចិត្តទូលំទូលាយ ក្នុងការឆ្លើយតប នៅចម្ងល់របស់សិស្ស មិនថាពេលវេលាណាក៏ដោយ។

នាងខ្ញុំមិនភ្លេចទេមិត្តភក្តិរួមជំនាន់ទី៩ទាំងអស់គ្នា ទោះបីពួកយើងមិនដែលបានជួបគ្នាផ្ទាល់ក៏ដោយ ប៉ុន្តែការស្រឡាញ់ រាប់អានគ្នាដោយទឹកចិត្តស្មោះត្រង់ មិនប្រកាន់អ្នកនៅខេត្ត ឬភ្នំពេញឡើយ។ ពួកយើងតែងតែចែករំលែកចំណេះដឹង បទពិសោធន៍ ឯកសារ និង ផ្តល់កម្លាំងចិត្តដល់គ្នាទៅវិញទៅមក ក្នុងការបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនេះ។ ហើយពួកយើងបានប្តេជ្ញា

ចិត្តថានឹងព្យាយាម តស៊ូ អត់ធ្មត់ ជំនះឧបសគ្គ ធ្វើយ៉ាងណាឱ្យការសិក្សារបស់ពួកយើងដល់គោលដៅទាំងអស់គ្នា។

ជាមួយគ្នានេះដែរ នាងខ្ញុំក៏សូមអរគុណជាពន្លឹក ដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ លោកនាយក លោកគ្រូអ្នកគ្រូ ដែលបានចូលរួមសហការ ចំណាយពេលវេលាដ៏មានតម្លៃរបស់ពួកគាត់ក្នុងការឆ្លើយសំណួរ ដោយយកចិត្តទុកដាក់ ប្រកបដោយសីលធម៌ថ្លៃថ្នូរ និងរួសរាយរាក់ទាក់។ ប្រសិនបើមិនមានពួកគាត់ទាំងអស់គ្នាជួយសហការ ផ្តល់មតិយោបល់ ការសរសេរនិក្ខេបបទរបស់នាងខ្ញុំ ប្រហែលជាមិនទទួលបានជោគជ័យតាមគោលដៅដែលបានកំណត់ទុកនោះឡើយ។

ជាចុងក្រោយ នាងខ្ញុំសូមជូនពរពួកគាត់ទាំងអស់គ្នា សូមឱ្យជួបតែសេចក្តីសុខ សេចក្តីចម្រើន រួចផុតទុក្ខកង្វល់ មានសុវត្ថិភាពក្នុងការធ្វើដំណើរទៅណាមកណា សូមទេវតាឆ្នាំថ្មី ជួយថែរក្សាពួកគាត់ ឱ្យជៀសផុសពីជំងឺ Covid-19 និងជំងឺកាចសាហាវផ្សេងៗទៀត។ ហើយសូមប្រសិទ្ធិពរជ័យដល់ពួកគាត់ទាំងអស់គ្នា ឱ្យជួបប្រទះពុទ្ធពរបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ «**ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ**» ក្នុងគោលបំណងសិក្សាស្វែងយល់អំពី ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្ស ហើយនិងការលើកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូនៅកម្រិតបឋមសិក្សា។

វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវនេះ គឺប្រើបរិមាណវិស័យ ។ ការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យគឺប្រើប្រាស់កម្រងសំណួរជាមួយគណៈគ្រប់គ្រង និងគ្រូបង្រៀន។ ដែលចំនួនសំណាកសរុប១៥១ នាក់ ។ សូចនាករសម្រាប់វាស់ទៅលើការចុះឈ្មោះសិស្សនៅកម្រិតបឋមសិក្សា គឺសំយោគទៅលើទ្រឹស្តីភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលា ការចុះឈ្មោះចូលរៀន និងការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀន។ នៅក្នុងសូចនាករភាពជាអ្នកដឹកនាំគ្រប់គ្រង បានបែងចែកជាសមាសភាព៥តូចៗដែលមាន កិច្ចគាំទ្រការរៀននិងបង្រៀន ការងាររដ្ឋបាល ការងារទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការ ការគ្រប់គ្រងបណ្ណាល័យ និង ការលើកទឹកចិត្តបុគ្គលិក។ សូចនាករធំបន្ទាប់គឺការអនុវត្តការងារពាក់ព័ន្ធទៅលើការចុះឈ្មោះសិស្សចូលរៀននៅកម្រិតបឋមសិក្សា។ សូចនាករចុងក្រោយគឺ ការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀននៅកម្រិតបឋមសិក្សា។

លទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា ការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ ពិតជាមានទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលាពិតប្រាកដមែន ដោយទិន្នន័យដែលទទួលបានពីនាយក និងគ្រូទៅលើភាពជាអ្នកដឹកនាំរបស់នាយកក្នុងកម្រិតល្អណាស់

(មធ្យមភាគពិន្ទុ៤.៣៦)។ ទិន្នន័យដែលទទួលបានពីសូចនាករបន្ទាប់គឺ ការងារពាក់ព័ន្ធទៅនឹងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សា ទិន្នន័យដែលទទួលបានពីនាយកនិងគ្រូ ក្នុងកម្រិតល្អណាស់ (មធ្យមពិន្ទុ៤.៥២) និង សូចនាករចុងក្រោយ គឺការងារពាក់ព័ន្ធនឹងការលើកកម្ពស់បរិយាកាស

បំពេញការងាររបស់គ្រូ ទិន្នន័យដែលទទួលបានពីនាយកនិងគ្រូ ក្នុងកម្រិតល្អណាស់ (មធ្យមពិន្ទុ៤.៣១) ដូចគ្នា។ ទោះបីជាទិន្នន័យដែលទទួលបានបង្ហាញថាល្អណាស់ក៏ដោយ តែក៏មានសូចនាករងមួយចំនួន

ដែលទាមទារឱ្យនាយកសាលាពង្រឹងបន្ថែមទៀតដូចជា៖ ការផ្តល់ធនធានដល់គ្រូបង្រៀន ឱ្យត្រូវតាមឯកទេសបង្រៀន ជំរុញសមត្ថភាពវិជ្ជាជីវៈរបស់គ្រូបង្រៀនលើការងារពិសោធន៍ កិច្ចកសាងវប្បធម៌សហការ និងការចូលរួម និង បង្កើតមូលនិធិសមធម៌អប់រំ ដើម្បីឱ្យការដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សមានប្រសិទ្ធភាពខ្ពស់។ ដូចនេះនាយកត្រូវមានយុទ្ធសាស្ត្រក្នុងការគ្រប់គ្រង និងផែនការក្នុងការផ្សព្វផ្សាយព័ត៌មាន តាមរយៈសហគមន៍ អាជ្ញាធរ ព័ត៌មានវិទ្យា ឬតាមបណ្តាញសង្គមជាដើម។ តាមរយៈការសិក្សាស្រាវជ្រាវលើប្រធានបទ «ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ» អាចទាញបានជាប្រយោជន៍ដល់នាយកសាលា ដើម្បីយកជាមេរៀនទៅជកបទពិសោធន៍ ក្នុងការពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រង និងការប្រមូលសិស្សចូលរៀនក្នុងសាលាឱ្យកាន់តែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។

**ពាក្យគន្លឹះ៖ ភាពជាអ្នកដឹកនាំគ្រប់គ្រង ការចុះឈ្មោះចូលរៀននៅបឋមសិក្សា**

# មាតិកា


សេចក្តីបញ្ជាក់របស់បេក្ខជន ........ i

សេចក្តីបញ្ជាក់របស់គ្រូណែនាំ ........ iii

សេចក្តីថ្លែងអំណរគុណ ........ vi

មូលន័យសង្ខេប ........ viii

បញ្ជីតារាង ........ xii

ជំពូកទី១៖ សេចក្តីផ្តើម ........ 1

១.១ លំនាំបញ្ហា ........ 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ៖ ( Research Problem ) ........ 3

១.៣ គោលបំណងនៃការស្រាវជ្រាវ៖ ( Research Objective ) ........ 5

១.៤ សំណួរស្រាវជ្រាវ ........ 6

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ៖ ( Contributions of Research ) ........ 6

១.៦ ដែនកំណត់ និង វិសាលភាពនៃការស្រាវជ្រាវ៖ ( Scope and Limitation ) ........ 7

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ៖ ( Structure of Research ) ........ 8

ជំពូកទី២ ៖ រំឭកទ្រឹស្តី ( Literature Review ) ........ 10

២.១ អ្នកដឹកនាំគ្រប់គ្រង ........ 10

២.១.១ សមត្ថភាពអ្នកដឹកនាំគ្រប់គ្រង: ........ 13

២.១.២ តួនាទីអ្នកដឹកនាំគ្រប់គ្រង ........ 14

២.២ ការចុះឈ្មោះចូលរៀន ........ 17

២.៣ ទំនាក់ទំនង ........ 18

២.៤ ការលើកកម្ពស់ក្នុងការបំពេញការងារ ........ 19

ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ ........ 21

៣.១ គម្រោងស្រាវជ្រាវ ( Research Design ) ........ 21

៣.១.១ ការសិក្សាស្រាវជ្រាវតាមបរិមាណវិស័យ៖ ........ 22

**៣.១.១.១ ទំហំសំណាក និងការជ្រើសំណាកៈ** ( Sample Size and Sampling Technique )....22
តារាង ៣.២ ចំនួនសំណាកនៃការចុះប្រមូលទិន្នន័យ....23
**៣.១.១.២ ឧបករណ៍សម្រាប់ការស្រាវជ្រាវៈ** ( Research Instrument )....23
៣.១.១.៣ កម្រិតចង្អុលបង្ហាញៈ....24
៣.១.១.៤ កម្រងសំណួរៈ....25
៣.១.១.៥ ការវិភាគទិន្នន័យតាមបរិមាណវិស័យ៖ ( Data Analysis )....27
**៣.២ ក្រមសីលធម៌នៃការស្រាវជ្រាវៈ**....28
**ជំពូកទី៤៖ លទ្ធផល និងពិភាក្សា**....29
**៤.១ ទិន្នន័យព័ត៌មានទូទៅៈ**....29
៤.១.១ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលារៀនៈ....29
៤.១.២ ព័ត៌មានទូទៅរបស់គ្រូបង្រៀនៈ....30
**៤.២ ភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលានៅកម្រិតបឋមសិក្សា**....30
៤.២.១ ទិន្នន័យដែលទទួលបាន....30
**៤.៣ ការអនុវត្តការងារពាក់ព័ន្ធការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា**....40
៤.៣.១ ទិន្នន័យដែលទទួលបាន....40
**៤.៤ លើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀននៅបឋមសិក្សា**....51
៤.៤.១ ទិន្នន័យដែលទទួលបាន....51
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**....56
**៥.១ សេចក្តីសន្និដ្ឋាន**....56
**៥.២ សំណូមពរ**....59
**ឯកសារយោង**....61
ឧបសម្ព័ន្ធ "ក"....64
ឧបសម្ព័ន្ធ "ខ"....72
ឧបសម្ព័ន្ធ "គ"....80

# បញ្ជីតារាង


តារាង ៣.១គម្រោងស្រាវជ្រាវរៀបរាប់ពីវិធីសាស្ត្រតាមបែបបរិមាណវិស័យ ................................21

តារាង៤.១ ៖ក. កិច្ចគាំទ្រការបង្រៀន និងរៀន ................................................................30

តារាង៤.២ ៖ ខ.ការងាររដ្ឋបាល ..........................................................................32

តារាង៤.៣ ៖ គ. ការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ................................................34

តារាង៤.៤ ៖ ឃ. ការគ្រប់គ្រងបណ្ណាល័យ ..........................................................................35

តារាង៤.៥ ៖ង. ការលើកទឹកចិត្ត...........................................................................37

តារាងសរុបរួម៤.៦៖  ភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកនៅកម្រិតបឋមសិក្សា....................38

តារាង៤.៧៖ ការអនុវត្តការងារពាក់ព័ន្ធការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា .....................40

តារាងទី៤.៨៖ តារាងពិភាក្សាលទ្ធផលនៃសំណួរស្រាវជ្រាវទី១ ...............................................43

តារាង៤.៩ ៖ ការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀននៅបឋមសិក្សា៖..........51

# ជំពូកទី១៖ សេចក្ដីផ្ដើម

## ១.១ លំនាំបញ្ហា

ក្នុងដំណើរឆ្ពោះទៅសង្គមពុទ្ធិ បដិវត្តន៍ឧស្សាហកម្មទី៤ និង ពលរដ្ឋសកល កម្ពុជាត្រូវពង្រឹងវិស័យអប់រំ ដើម្បីឱ្យពលរដ្ឋរបស់ខ្លួន បានឆ្លងកាត់ប្រព័ន្ធអប់រំ ដែលមានកញ្ចប់សមត្ថភាព ចេះធ្វើការងារជាក្រុម ប្រាស្រ័យទាក់ទង ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ការរស់នៅចម្រុះវប្បធម៌ និងជាតិសាសន៍ ។ល។ វិស័យអប់រំមានតួនាទី និង ភារកិច្ចសំខាន់ណាស់ ក្នុងការកសាងធនធានមនុស្សដើម្បីរួមចំណែក អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមពុទ្ធិ។ ក្រសួង អប់រំ យុវជន និង កីឡា បានដាក់ចេញ គោលនយោបាយ **ការសិក្សាពេញមួយជីវិត** គឺចង់ឱ្យប្រជាពលរដ្ឋកម្ពុជាទាំងអស់មានឱកាសទទួលការអប់រំគ្រប់ៗគ្នា ដោយមិនគិតពីអាយុ ភេទ តួនាទី ស្របទៅនឹងការប្រែប្រួលទីផ្សារការងារ នឹងក្លាយជាសមាសភាពសំខាន់ក្នុងគោលដៅទី៤ នៃក្របខណ្ឌគោលដៅអភិវឌ្ឍ ប្រកបដោយចីរភាពឆ្នាំ២០៣០ ដែលធានាឱ្យបាន ការអប់រំមានគុណភាព ប្រកបដោយសមធម៌ និង បរិយាបន្ន (ក្រសួង អប់រំ យុវជន និង កីឡា, ២០១៩)។ បន្ថែមពីនេះក្រសួងអប់រំ យុវជន និងកីឡាក៏បានគិតគូរទៅលើ **ការគាំពារកុមារ និងការអភិវឌ្ឍកុមារ** ដែលជាគុណប្រយោជន៍ដល់អនាគតកុមារម្នាក់ៗ ដើម្បីក្លាយខ្លួនជាទំពាំងស្នងឫស្សីរបស់ប្រទេសជាតិ។ ដើម្បីធានាឱ្យបានធនធានមនុស្សដែលប្រកបដោយគុណភាព និងមានផលិតភាពការងារខ្ពស់ គឺជាស្ពានចម្លងឆ្ពោះទៅសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវការអភិវឌ្ឍមនុស្សឱ្យមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និង គុណតម្លៃ។ លោកគ្រូអ្នកគ្រូត្រូវតែផ្ដល់សេវាអប់រំប្រកបដោយគុណភាព និងការផ្ដល់សេវាសុខភាពប្រកបដោយស្មារតីទទួលខុសត្រូវគឺជាសូចនាករដែលរាជរដ្ឋាភិបាលកំពុងអនុវត្ត (ក្រសួងអប់រំ យុវជន និង កីឡា, ២០១០)។ ដើម្បីសម្រេចតាមចក្ខុវិស័យរបស់ រាជរដ្ឋាភិបាល ក្រសួង អប់រំ យុវជន និង កីឡា និងសប្បុរសជន បានសាងសង់សាលាជាច្រើន ដើម្បីបង្ខិតសាលារៀនឱ្យជិតទីលំនៅរបស់សិស្សានុសិស្ស ជាពិសេសសិស្សដែលជួបការលំបាក។ តាមរយៈការធ្វើយុទ្ធនាការប្រមូលសិស្សចូលរៀនឱ្យបានគ្រប់គ្នាៗ។ ការសាងសង់អគារ ការផ្ដល់ថវិកាដំណើរការសាលារៀន ផ្ដល់ថវិកាអាហារូបករណ៍សិស្សក្រីក្រ ជាពិសេសគឺសិស្សនារី ដើម្បីបង្កភាពងាយស្រួលដល់សិស្សបានទទួលសេវាអប់រំគ្រប់ៗគ្នា។

នាយក គ្រូបង្រៀន ហេដ្ឋារចនាសម្ព័ន្ធ រូបវន្ត សាលារៀន សម្ភារសិក្សា និងប្រព័ន្ធអប់រំ សុទ្ធសឹងតែជាធនធានមូលដ្ឋាន សម្រាប់ដំណើរការអប់រំឱ្យមានប្រសិទ្ធភាព។ ក្នុងនោះ នាយកសាលា គ្រូបង្រៀន គឺជាកត្តាគន្លឹះធំបំផុតក្នុងការកសាងធនធានមនុស្ស ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងពង្រឹងសមត្ថភាពរបស់ខ្លួនជាប្រចាំ។ លោកនាយក លោកគ្រូអ្នកគ្រូ និងអ្នកឯកទេស ជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់គុណភាពអប់រំ ។ គុណសម្បទារបស់លោកគ្រូអ្នកគ្រូ ដើម្បីធានាប្រសិទ្ធភាពការងារ ដែលបានចែងក្នុង ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។ លោកគ្រូអ្នកគ្រូ គណៈគ្រប់គ្រង សាលារៀន និង អ្នកឯកទេសអប់រំ ជាចលករដែលមិនអាចខ្វះបានក្នុងការផលិតធនធានមនុស្ស ដែលជាកម្លាំងពលកម្មសកម្ម និងមានផលិតភាពសេដ្ឋកិច្ចខ្ពស់ សម្រាប់ធានាកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។ ដើម្បីធានាឱ្យបានគ្រូល្អ ដែលមានសមត្ថភាព មានចំណេះដឹង ជំនាញ និងចេះបច្ចេកវិទ្យា ក្រសួងអប់រំបានដាក់ចេញ **ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន** ដើម្បីទាក់ទាញ និងលើកទឹកចិត្តពលរដ្ឋពូកែៗឱ្យចាប់អារម្មណ៍ ស្រឡាញ់ចូលចិត្តអាជីពជាគ្រូបង្រៀន និងរក្សាគ្រូបង្រៀនល្អ នាយកល្អ និងអ្នកឯកទេសអប់រំជំនាញ ដើម្បីបម្រើការងារក្នុងប្រព័ន្ធអប់រំ។ គ្រូបង្រៀនត្រូវបានបណ្តុះបណ្តាល និង អភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនជាបន្តបន្ទាប់ឥតឈប់ឈរ ព្រោះគ្រូបង្រៀនជាវិស្វករ ជាអ្នកអប់រំដែលមានសមត្ថភាព មានស្មារតីទទួលខុសត្រូវប្រកបដោយព្រហ្មវិហារធម៌ចំពោះសិស្ស(ក្រសួង អប់រំ យុវជន និង កីឡា, ២០១៨)។ ម៉្យាងទៀតគ្រូបង្រៀន ជាចំណែកមួយក្នុងការទាក់ទាញអត្រាចុះឈ្មោះសិស្សចូលរៀនក្នុងសាលាសាធារណៈកាន់តែច្រើនឡើង ប្រសិនបើគ្រូបង្រៀនមានសម្តីផ្អែមល្ហែម ម៉ឺងម៉ាត់ រួសរាយរាក់ទាក់ មិនរំលោភបំពានលើសិទ្ធិសេរីភាពកុមារ មិនប្រើប្រាស់អំពើហិង្សា មិនរើសអើង មិនដាក់ទណ្ឌកម្ម លើកុមារនោះទេ។ ជាពិសេសអ្វីដែលមិនអាចខ្វះបានគឺអ្នកដឹកនាំគ្រប់គ្រង នៅក្នុងអង្គភាពមួយអាចដំណើរការទៅបាន ដោយមានប្រសិទ្ធភាព លុះត្រាតែមានអ្នកដឹកនាំ អ្នកគ្រប់គ្រងរឹងមាំ ឈ្លាសវៃ អត់ធ្មត់ មានចំណេះដឹង មានការច្នៃប្រឌិតនិង នវានុវត្ត មានទំនាក់ទំនងល្អរវាងថ្នាក់ដឹកនាំ សហគមន៍ អាជ្ញាធរ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និង មាតាបិតាសិស្ស ។ អ្នកដឹកនាំគ្រប់គ្រងត្រូវមានមនសិកា ឆន្ទៈ មានគោលដៅ ផែនការ និង សកម្មភាពច្បាស់លាស់ក្នុងការអភិវឌ្ឍសាលារបស់ខ្លួន (ក្រសួង អប់រំ យុវជន និង កីឡា, ២០១៧)។ នៅដើមឆ្នាំសិក្សានៅគ្រប់សាលាសា

ជារណៈទូទាំងខេត្តក្រុង បានបើកយុទ្ធនាការផ្សព្វផ្សាយការចុះឈ្មោះចូលរៀន និងជំរុញការបន្តការសិក្សារបស់សិស្សគ្រប់កម្រិត ក្នុងគោលបំណងកើនរំលឹកមាតាបិតា អាណាព្យាបាល ក្នុងការនាំកូនគ្រប់អាយុ ទៅចុះឈ្មោះចូលរៀននិង ជំរុញលើកទឹកចិត្តដល់សិស្សានុសិស្សឱ្យបន្តការសិក្សា(ក្រសួង អប់រំ យុវជន និងកីឡា,២០១៦)។ បច្ចុប្បនេះការអប់រំមានការរីកចម្រើនគួរជាទីមោទនៈ ទាំងសាលាសាធារណៈ និង ឯកជន។ ប៉ុន្តែ អត្រានៃការចុះឈ្មោះចូលរៀនរបស់សិស្សនៅបឋមសិក្សាសាធារណៈក្នុងរាជធានីភ្នំពេញនៅមិនទាន់ដល់ចំណុចដៅនៅឡើយ(ក្រសួង អប់រំ យុវជន និង កីឡា, ២០២១-២០២២)។ ជាក់ស្តែងនៅអង្គភាពដែលនាងខ្ញុំបម្រើការងារឃើញថាមានសិស្សចុះឈ្មោះចូលរៀនមានការថយចុះពីមួយឆ្នាំទៅមួយឆ្នាំ ហេតុសឹងតែគ្មានសិស្សបង្រៀនទៅហើយ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ៖(Research Problem)

ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីពីការអប់រំឆ្នាំ២០៣០ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដែលមានគោលនយោបាយពីរ គឺ ១) ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និង លើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង ២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់(ក្រសួង អប់រំ យុវជន និងកីឡា ,២០០៨)។

តាមរយៈក្របខណ្ឌសមត្ថភាពនាយកសាលារៀននៅអាស៊ីអាគ្នេយ៍ បានសរសេរថាៈ សមត្ថភាពនាយកចែកចេញជា៥មានដូចជាៈ ១) គំនិតជាយុទ្ធសាស្ត្រ និងនវានុវត្ត ២) ភាពជាអ្នកដឹកនាំគ្រប់គ្រង ៣) ភាពជាអ្នកដឹកនាំការបង្រៀន និងរៀន ៤) ឧត្តមភាពផ្ទាស់ខ្លួន ៥) ការចូលរួមពីភាគីពាក់ព័ន្ធ ។ សមត្ថភាពជោគជ័យនេះ កំណត់បាននូវការរំពឹងទុកនៃតួនាទីរបស់នាយកសាលារៀន និងផ្តល់មូលដ្ឋានគ្រឹះត្រឹមត្រូវមួយសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈនាយកសាលារៀន។ (ក្រសួង អប់រំ យុវជន និងកីឡា, ២០១៤)

ភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលា គឺត្រូវមានភាពស្វាហាប់ និងផ្លាស់ប្តូរជានិច្ច។ រចនាបទភាពជាអ្នកដឹកនាំគ្រប់គ្រងមានភាពស្មុគ្រស្មាញ និងដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវប្បធម៌នៅក្នុងសាលា(Fullan, 2001)។

ការគ្រប់គ្រងតាមសាលារៀន ជាយន្តការដ៏មានប្រសិទ្ធភាពមួយក្នុងការអនុវត្តវិមជ្ឈការនៃការអប់រំដើម្បីធានាឱ្យសេវាអប់រំមានប្រសិទ្ធភាពខ្ពស់។ ការគ្រប់គ្រងតាមសាលារៀនត្រូវបានបែងចែកជាៈ ១) ប្រកួតប្រជែង ការពិនិត្យ និងតុល្យភាពផ្ទៃក្នុងរបស់ក្រសួងអប់រំ យុវជន និងកីឡា រួមមានការផ្តល់ធនធានសិទ្ធិអំណាច និងការកសាងសមត្ថភាពដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្ស ២) ធ្វើឱ្យក្រសួងអប់រំ យុវជន និងកីឡាអាចឆ្លើយតបបានច្រើនជាងមុន ក្នុងការផ្តល់សេវាកម្មអប់រំនៅសាលារៀន និងក្នុងការដោះស្រាយបញ្ហាបានទាន់ពេល និងមានប្រសិទ្ធភាពខ្ពស់ ៣)កាត់បន្ថយភាពតានតឹងសង្គម និងនយោបាយធានាបាននូវស្វ័យភាព និងតម្លាភាពមូលដ្ឋាន ដោយសារតែសាធារណជនបានរួមចំណែកទទួលខុសត្រូវ និងដោះស្រាយជាមួយរដ្ឋ។ ក្នុងន័យនេះការគ្រប់គ្រងសាលារៀន គឺការផ្តល់ស្វ័យភាពក្នុងការសម្រេចចិត្តទៅកម្រិតមូលដ្ឋាន ដោយផ្អែកលើលទ្ធផលនៃការអនុវត្តការងាររបស់សាលារៀន និងលទ្ធផលសិក្សារបស់សិស្ស។ ប្រការនេះជាជំហរអនុវត្តនូវការសម្រេចចិត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឱ្យសាលារៀនទាំងអស់អាចសម្រេចបានតាមស្តង់ដាទាំង៩ស្តីពីសាលារៀនមានប្រសិទ្ធភាព(ក្រសួង អប់រំ យុវជន និងកីឡា,២០១៨)។

សាលាកុមារមេត្រី គឺជាក្របខណ្ឌទូលំទូលាយមួយដែលមានគ្រប់ផ្នែកនៃការងារទាំងអស់របស់សាលារៀន រួមមានការគ្រប់គ្រងសាលារៀន សុខភាព និងសុវត្ថិភាព យេនឌ័រ ទំនាក់ទំនងសាលារៀនសហគមន៍ និងការគាំទ្ររបស់ប្រព័ន្ធអប់រំ(ក្រសួង អប់រំ យុវជន និងកីឡា,២០០៥)។

ការអប់រំមូលដ្ឋានគឺជាសិទ្ធិរបស់កុមារ។ សិទ្ធិនេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានសន្យាផ្តល់ការអភិវឌ្ឍជាជំហានៗលើការអប់រំចាប់ពីកុមារអាយុសូន្យឆ្នាំ រហូតដល់ធ្វើឱ្យកុមារគ្រប់រូបសម្រេចបានលទ្ធផលសិក្សាប្រកបដោយគុណភាព

និងសមធម៌។ រាជរដ្ឋាភិបាលបានប្រើប្រាស់គ្រប់មធ្យោបាយក្នុងដំណើរការពង្រឹង និងពង្រីកគុណភាពអប់រំឱ្យស្របតាមគោលដៅ និងចំណុចដៅនានាដែលបានកំណត់។ ក្នុងដំណើរការអភិវឌ្ឍសាលាបានល្អ គឺអាស្រ័យទៅលើការចូលរួមរបស់លោកគ្រូអ្នកគ្រូ នាយកសាលា ដែលជាសមាសភាពសំខាន់បំផុតក្នុងការលើកម្ពស់គុណភាពអប់រំនៅកម្រិតបឋមសិក្សាក្នុងព្រះរាជាណាចក្រកម្ពុជា។ សាលារៀនដើរតួយ៉ាងសំខាន់ ជាវេទិកាសេរី ប្រជាធិបតេយ្យ ដែលផ្តល់ឱកាសដល់លោកគ្រូ អ្នកគ្រូ នាយកសាលា និងសិស្សានុសិស្ស បានបញ្ចេញមតិ ពិភាក្សា ផ្លាស់ប្តូរយោបល់ អំពីការងារអប់រំនៅក្នុងមូលដ្ឋានរៀងៗខ្លួន និងបង្ហាញពីតួនាទីសំខាន់បំផុតរបស់សហគមន៍ ក្នុងការអភិវឌ្ឍសាលា (ក្រសួង អប់រំ យុវជន និងកីឡា, ២០១០)។ នាយកសាលាល្អ គ្រូបង្រៀនមានគុណភាព មាតាបិតាសិស្សមានជំនឿចិត្តក្នុងការចុះឈ្មោះកូនចៅរបស់ពួកគេ។

ដោយយល់ឃើញថានាយកសាលា ពិតជាមានទំនាក់ទំនង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សា ទើបអ្នកសិក្សាស្រាវជ្រាវលើកយកប្រធានបទ « **ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ** » មកស្រាវជ្រាវ ដើម្បីជាប្រយោជន៍ដល់គណៈគ្រប់គ្រង គ្រូ មាតាបិតា សិស្សានុសិស្ស និងអ្នកពាក់ព័ន្ធផ្សេងទៀត យកទៅអនុវត្ត។

### **១.៣ គោលបំណងនៃការស្រាវជ្រាវ** ( Research Objective )

ប្រធានបទ «**ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ** » មានគោលបំណងពីរគឺ:

- ដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ
- ស្វែងយល់ពីការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀននៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ

## ១.៤ សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងគោលបំណងខាងលើ អ្នកសិក្សាស្រាវជ្រាវផ្តោតទៅលើសំណួរស្រាវជ្រាវចំនួនពីរៈ

១. តើទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាយ៉ាងដូចម្តេចខ្លះ ?

២.តើអ្នកដឹកនាំគ្រប់គ្រងធ្វើដូចម្តេច ដើម្បីលើកកម្ពស់បរិយាកាសការបំពេញការងាររបស់គ្រូបង្រៀននៅកម្រិតបឋមសិក្សា ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវៈ(Contributions of Research)

ការសិក្សាទៅលើប្រធានបទ «**ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និង ការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ**» នេះពិតជាមានសារៈសំខាន់ ពីព្រោះសិស្សានុសិស្សទាំងអស់ មុននឹងទទួលបានជោគជ័យក្នុងការសិក្សា ពួកគេសុទ្ធតែឆ្លងកាត់ការបណ្តុះបណ្តាលនៅកម្រិតបឋមសិក្សា ដែលជាមូលដ្ឋានគ្រឹះ ប្រសិនបើអ្នកចាក់គ្រឹះបានរឹងមាំពីកម្រិតបឋមសិក្សាទៅ មធ្យមសិក្សា ឬឧត្តមសិក្សាមិនសូវមានសិស្សបោះបង់ការសិក្សាច្រើន។ ម្យ៉ាងទៀតប្រសិនបើមិនមានសិស្សចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា តើមធ្យមសិក្សា និង ឧត្តមសិក្សាមានសិស្សមកពីណារៀន។ សរុបមកវិញការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាពិតជាមានសារៈសំខាន់ ដោយផ្សារភ្ជាប់ជាមួយនឹងការដឹកនាំគ្រប់គ្រងរបស់នាយកសាលា ទើបទទួលបានជោគជ័យ (Hoy and Smith, 2007) ។ នាយកសាលាត្រូវមានក្រមសីលធម៌វិជ្ជាជីវៈជាអ្នកដឹកនាំ ដែលមានសមត្ថភាព ចំណេះដឹងលើបច្ចេកវិទ្យា មានឆន្ទៈ អត់ធ្មត់ មានសុខភាពល្អ មានធនធានកាន់តែប្រសើរ ចេះសម្របគ្រប់កាលៈទេសៈ គោរពតួនាទី និងភារៈកិច្ចរបស់ខ្លួនក្នុងការដឹកនាំគ្រប់គ្រប់បុគ្គលិកក្រោមបង្គាប់ ជាពិសេសត្រូវតែសហការជាមួយភាគីដែលពាក់ព័ន្ធ ស្តាប់យោបល់គ្នា យោគយល់គ្នា កែលម្អគ្នា ក្នុងគោលដៅតែមួយគឺអភិវឌ្ឍសាលាឱ្យចំនួនសិស្សពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងជាលំដាប់នេះទើបជាភាពជោគជ័យរបស់សាលាទាំងមូល។ សរុបមកវិញអ្នកដឹកនាំគ្រប់គ្រងពិតជាមានសារៈសំខាន់ ក្នុងការដឹកនាំបុគ្គលិករបស់ខ្លួនឱ្យមានឆន្ទៈ មនសិការ មានការទទួលខុសត្រូវចំពោះភារៈកិច្ចរបស់ខ្លួន ដើរបានគោល

គំនិតតែមួយគឺមានស្មារតីចង់ឃើញសាលារបស់ខ្លួនមានការអភិវឌ្ឍ និងរីកចម្រើនទៅមុខ(ក្រសួង អប់រំ យុវជន និងកីឡា, ២០១៧)។

ម្យ៉ាងវិញទៀតបានជាប្រយោជន៍ដល់ក្រសួងអប់រំ យុវជននិង កីឡារាជធានីភ្នំពេញ ឱ្យបាន ឃើញពីតថភាពជាក់ស្តែង ដែលបានមកពីលទ្ធផលស្រាវជ្រាវមួយនេះ និង ចាត់វិធានការសមស្របណា មួយដើម្បីរួមចំណែកជាមួយសាលា អាជ្ញាធរ និងអ្នកពាក់ព័ន្ធ ដើម្បីចាត់វិធានការប្រមូលសិស្សទាំងអស់ ឱ្យមកចុះឈ្មោះចូលរៀនគ្រប់ៗគ្នា។ បន្ថែមពីនេះត្រូវលើកទឹកចិត្តបុគ្គលិកល្អៗដែលមានសមត្ថភាពក្នុង ការដឹកនាំគ្រប់គ្រង ឱ្យពួកគាត់សាកល្បងសមត្ថភាពរបស់ខ្លួនប្រកបដោយចំណេះដឹង ជំនាញថ្មីៗ ដែល បានសិក្សាស្រាវជ្រាវ ស្របតាមបំណិនសតវត្សទី២១ ដែលមានបីសំខាន់ ១).បំណិនក្នុងការសិក្សារៀន សូត្រ ផ្តោតទៅលើការត្រិះរិះពិចារណា ការគិតដោយមានការច្នៃប្រឌិត ការសហការ និងការទំនាក់ទំនង ២).បំណិននៃការទទួលព័ត៌មានថ្មីៗ ចំណេះផ្នែកព័ត៌មានវិទ្យា ចំណេះផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងចំណេះ ដឹងផ្នែកបច្ចេកវិទ្យា ៣). បំណិនជីវិត ផ្តោតទៅលើការរស់នៅចុះសម្រុះជាមួយអ្នកដទៃ ការចេះផ្តួចផ្តើមគំនិត ភាពជាអ្នកដឹកនាំ និងផលិតភាពការងារ។ បំណិនទាំងអស់នេះសំខាន់ណាស់ក្នុងសម័យសេដ្ឋកិច្ចពឹងផ្អែក លើបច្ចេកវិទ្យាព័ត៌មាន។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយជំរុញឱ្យប្រទេសកម្ពុជា ក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងក្លាយជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ (ក្រសួង អប់រំ យុវជន និងកីឡា, ២០២១)។

## ១.៦ ដែនកំណត់ និង វិសាលភាពនៃការស្រាវជ្រាវ៖(Scope and Limitation)

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ « **ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ** » អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើស ៣ខណ្ឌ និង៦សាលា នៅក្នុងរាជធានីភ្នំពេញ មានដូចជាៈ សាលាបឋមហ៊ុនសែនចាក់អង្រែ និងបឋម សិក្សាចាក់អង្រែភូមិ៣ ដែលស្ថិតក្នុងខណ្ឌមានជ័យ។ សាលាបឋមសិក្សាប្រាំងចំរេះ និងសាលាបឋម សិក្សាហ៊ុនសែនចំរើនរដ្ឋ ស្ថិតក្នុងខណ្ឌឫស្សីកែវ។ សាលាបឋមសិក្សាភ្នំដូនពេញ និងបឋមសិក្សាអនុវត្ត

ស្ថិតក្នុងខណ្ឌដូនពេញ ។ អ្នកស្រាវជ្រាវជ្រើសរើសបែបកណ្តាលទីក្រុង ទីប្រជុំជន និង ជាយក្រុង ដើម្បីទទួលបានទិន្នន័យចម្រុះ ហើយដាក់លាក់ដូចការរំពឹងទុក។ ការស្រាវជ្រាវទៅលើប្រធានបទនេះអនុវត្តតាមវិធីសាស្ត្របែបបរិមាណវិស័យ។ ហើយការស្រាវជ្រាវទៅលើប្រធានបទនេះ ផ្តោតទៅលើ ទំនាក់ទំនងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀន(សិស្សគ្រប់អាយុត្រូវចូលរៀន សិស្សចុះឈ្មោះចូលរៀនតាមកម្រិតថ្នាក់ និងសិស្សផ្ទេរការសិក្សា) និង ការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូ។

**១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ៖**( Structure of Research )

រចនាសម្ព័ន្ធនៃការស្រាវជ្រាវ មាន៥ជំពូក:

- **ជំពូកទី១៖** ចំណុចបង្ហាញរួមមានៈ ១)លំនាំបញ្ហានៃការស្រាវជ្រាវ ២)ចំណោទបញ្ហានៃការស្រាវជ្រាវ ៣)គោលបំណងនៃការស្រាវជ្រាវ ៤)សំណួរស្រាវជ្រាវមានចំនួនពីរដែលឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវ ៥)សារៈសំខាន់នៃការស្រាវជ្រាវ ទាញបានសេចក្តីសន្និដ្ឋាន និងសំណូមពរសម្រាប់ជំរុញឱ្យការដឹកនាំគ្រប់គ្រង និងការចុះឈ្មោះសិស្សចូលរៀននៅបឋមសិក្សាក្នុងរាជធានីភ្នំពេញបានប្រសើរឡើង ៦)ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ៧)រចនាសម្ព័ន្ធនៃការស្រាវជ្រាវ
- **ជំពូកទី២៖ រំឭកទ្រឹស្តី** រំឭកពាក្យគន្លឹះដូចជា ( ភាពជាអ្នកដឹកនាំគ្រប់គ្រង ទំនាក់ទំនងការចុះឈ្មោះចូលរៀន និងការលើកកម្ពស់បរិយាកាសបំពេញការងារ)
- **ជំពូកទី៣ ៖** បង្ហាញពីវិធីសាស្ត្រស្រាវជ្រាវ ការវិភាគទ្រឹស្តីដែលឆ្លុះបញ្ចាំងលើការអនុវត្តជាក់ស្តែង។ វិធីសាស្ត្រស្រាវជ្រាវចំនួនមួយ គឺបរិមាណវិស័យ(កម្រងសំណួរ)
- **ជំពូកទី៤៖** បង្ហាញពីលទ្ធនៃការស្រាវជ្រាវ ទៅលើសំណួរស្រាវជ្រាវទាំងពីររួចធ្វើការវិភាក្សាសំយោគបញ្ចូលគ្នាដើម្បីសិក្សាទៅលើទំនាក់ទំនងភាពជាអ្នកដឹកនាំគ្រប់គ្រង និង ការចុះឈ្មោះសិស្សចូលរៀន។

- **ជំពូកទី៥៖** ការធ្វើសេចក្តីសន្និដ្ឋានទៅលើលទ្ធផល ដែលទទួលបានពីកម្រងសំណួរ ហើយដាក់ជូនដល់ភាគីពាក់ព័ន្ធ

# ជំពូកទី២ ៖ រំឭកទ្រឹស្តី( Literature Review )

## ២.១ អ្នកដឹកនាំគ្រប់គ្រង

អ្នកដឹកនាំគ្រប់គ្រងជាការងារមួយដែលមានសកម្មភាពផ្សេងៗគ្នាជាច្រើន។ ឧទាហរណ៍ ការដឹកនាំគ្រប់គ្រងរបស់រាជរដ្ឋាភិបាលគឺការដឹកនាំប្រទេសទាំងមូល អ្នកដឹកនាំគ្រប់គ្រងគ្រួសារគឺជាមេផ្ទះ និងអ្នកដឹកនាំគ្រប់គ្រងអង្គភាពជាដើម។ ការងារដឹកនាំនឹងគ្រប់គ្រងមិនដូចគ្នាទេ ទៅតាមប្រទេស គ្រួសារ និងអង្គភាពដែលពួកគេរស់ ឬពួកគេកំពុងបម្រើការងារនៅជាក់ស្តែង។ ប៉ុន្តែ**អ្នកដឹកនាំ** ( Leader )ក្នុងន័យអប់រំគឺសំដៅទៅលើអ្នកបណ្តុះបណ្តាល ជំរុញមនុស្សឱ្យមានការរីកចម្រើន មានការប្រែប្រួល មានជំនឿ ការជឿជាក់ និងធ្វើសកម្មភាពរបស់ខ្លួនជាប្រចាំ ដើម្បីជួយឱ្យសាលារៀនក្លាយជាកន្លែងមួយកាន់តែល្អប្រសើរសម្រាប់សិស្សានុសិស្សគ្រប់មជ្ឈដ្ឋាន។ ន័យម្យ៉ាងទៀតសំដៅដល់អ្នកទទួលខុសត្រូវ អភិបាលកិច្ច ក្នុងការប្រើប្រាស់ធនធាននានា របស់អង្គភាពឱ្យសម្រេចគោលដៅ។ អ្នកគ្រប់គ្រងត្រូវបើកមាត់ ត្រចៀក ស្តាប់ហើយគិត បើនិយាយស្តីត្រូវនិយាយឱ្យល្អ ពិរោះ ឱ្យបុគ្គលិកយល់ និយាយរឿងលំបាកឱ្យទៅជាស្រួលវិញ។ ឬអាចនិយាយឱ្យខ្លីថា អ្នកគ្រប់គ្រងល្អ គឺជាមនុស្សដែល ចេះលៃលក កែលម្អ ឬផ្លាស់ប្តូរ ដោយរកនូវវិធីសាស្ត្រថ្មីៗនិងមានប្រសិទ្ធភាព( ក្រសួង អប់រំ យុវជន និងកីឡា, ២០១៧ )។

ចំណែកឯលោក JOHN C. MAXWELL, ( 2018 ) បានឱ្យនិយមន័យ ភាពជាអ្នកដឹកនាំមាន៥កម្រិត

១. អ្នកដឹកនាំត្រូវការមុខតំណែង: ជាចំណុចចាប់ផ្តើមនៃភាពជាអ្នកដឹកនាំ និងត្រូវអភិវឌ្ឍ។

២. អ្នកដឹកនាំត្រូវការ ការទទួលស្គាល់: ជាការបង្កើតសម្ព័ន្ធភាពរវាងក្រុមការងារ ដើម្បីឱ្យមានការទទួលស្គាល់។

៣. អ្នកដឹកនាំត្រូវការ កសាងសមិទ្ធិផល: ការបញ្ចេញថ្វីដៃរួមទាំងធ្វើឱ្យក្រុមការងារសាងសមិទ្ធិផលរបស់ខ្លួន។

៤. អ្នកដឹកនាំត្រូវការ ការអភិវឌ្ឍធនធានមនុស្ស: ប្រឹងប្រែងអភិវឌ្ឍអ្នកដទៃឱ្យក្លាយជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពខ្ពស់។

៥. អ្នកដឹកនាំត្រូវការ កម្រិតខ្ពស់បំផុតៈ ជាអ្នកដឹកនាំពេញលក្ខណៈ។

លោកនាយកអាចសាកល្បងវាយតម្លៃខ្លួនឯង តើសមត្ថភាពរបស់ខ្លួនស្ថិតក្នុងកម្រិតទីប៉ុន្មាន ហើយមានចំណុចខ្លាំង និង ចំណុចខ្សោយត្រង់ណា? ដើម្បីងាយស្រួលក្នុងការអភិវឌ្ឍខ្លួនឯងឱ្យឆ្លងផុតពីកម្រិតនីមួយៗបាន។

យោងតាមសារព័ត៌មានរបស់ Clubniset, (2011) បានឱ្យនិយមន័យមួយបែបទៀតថា **អ្នកដឹកនាំ** គឺជាមនុស្សម្នាក់ដែលមានឥទ្ធិពលទៅលើអ្នកដទៃដើម្បីសម្រេចបានគោលដៅ និង ជាអ្នកសម្របសម្រួលឱ្យមានការផ្លាស់ប្តូរ មានការលើកទឹកចិត្តមនុស្សដើម្បីពុះពារឧបសគ្គ និងធ្វើអោយអង្គភាពឆ្ពោះទៅរកភាពល្អឥតខ្ចោះក្នុងថ្ងៃអនាគត។ ម្យ៉ាងទៀត អ្នកដឹកនាំដែលខ្លាំងពូកែ គឺត្រូវមានចក្ខុវិស័យច្បាស់លាស់ និង ត្រូវចេះរៀបចំផែនការណ៍យុទ្ធសាស្ត្របានល្អ ឱ្យមានប្រសិទ្ធភាពខ្ពស់ទៅលើដំណើរការរបស់បុគ្គលិក ដើម្បីប្រតិបត្តិយុទ្ធសាស្ត្រនិងចក្ខុវិស័យនោះ ឱ្យទទួលបានលទ្ធផលល្អ ។

រីឯសារព័ត៌មាន KHSearch, (2017)បានឱ្យនិយមន័យ **ភាពជាអ្នកដឹកនាំ** ថាជាសមត្ថភាពដែលអាចឬជំរុញអ្នកឯទៀតក្នុងក្រុម ក្នុងអង្គភាព ក្នុងស្ថាប័ន ឲ្យពួតដៃគ្នាធ្វើការងារឱ្យសម្រេចគោលដៅ។ ឬក៏មានន័យម្យ៉ាងទៀតថា គឺជាបុគ្គលដែលត្រូវបានទទួលស្គាល់ពីសមាជិកក្រុមក្នុងអង្គភាព ដើម្បីឲ្យគេធ្វើជាអ្នកដឹកនាំក្រុម អនុវត្តការងារឲ្យសម្រេចគោលបំណងដែលគេបានគ្រោងទុក។

តាមរយៈសារព័ត៌មាន ថ្មីៗ ២០១៥ បានឱ្យនិយមន័យស្រដៀងនិងការឱ្យនិយមន័យរបស់អ្នកខាងលើដែល**ភាពជាអ្នកដឹកនាំ** គឺសំដៅលើបុគ្គលដែលមានឥទ្ធិពលក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការព្រមទាំងបង្កើតយុទ្ធសាស្ត្រ ដើម្បីឲ្យអ្នកក្រោមបង្គាប់អនុវត្តតាមប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាពនៃការងារ។

តាមរយៈនិយមន័យដ៏សាមញ្ញរបស់លោកស្រី Susan Ward, (2019)ក៏មិនខុសពីគេដែល **ភាពជាអ្នកដឹកនាំ** ជាសិល្បៈនៃការជំរុញឱ្យក្រុមមនុស្សមួយក្រុមដើរឆ្ពោះទៅរកការសម្រេចគោលដៅរួមមួយ ។

លោក Li yang Pich, (2011)ដែលបានសរសេរចែកចាយតាមប្រព័ន្ធGoogle ថា **អ្នកដឹកនាំ** គឺជាបុគ្គលដ៏សំខាន់ក្នុងការចង្អុលបង្ហាញផ្លូវ ជាអ្នកអភិវឌ្ឍ អ្នកផ្លាស់ប្តូរ រឺlead អ្នកក្រោមបង្គាប់ រឺ follower ឱ្យត្រងត្រាប់ និងអនុវត្តតាមឆ្ពោះទៅរកការសម្រេចគោលដៅរួមមួយ ។ មិនថាតែអ្នកដឹកនាំ រឺបុគ្គលដែលត្រូវគេដឹកនាំនោះទេ ការស្តាប់គឺជាសកម្មភាពដ៏សំខាន់ក្នុងការទំនាក់ទំនង និងចែកចាយព័ត៌មាន ជាពិសេសចំពោះការគ្រប់គ្រងចាត់ចែង និងការបង្កើតបរិយាកាសសមស្របមួយ ដើម្បីអោយអ្នកក្រោមបង្គាប់ ចូលរួមបំពេញការងារយ៉ាងសកម្ម ។ យ៉ាងណាមិញ គេតែងសង្កេតឃើញថា អ្នកដឹកនាំដ៏អស្ចារ្យ គឺជាអ្នកស្តាប់ដ៏ពូកែ។

លោក Tony Bush is Professor of Educational Leadership at Nottingham, (2021) បានឱ្យនិយមន័យ **អ្នកដឹកនាំគ្រប់គ្រង** ពិតជាមានសារៈសំខាន់បំផុតនាសតវត្សទី២១នេះ ។ ភាពល្បីល្បាញរបស់អង្គភាពមួយគឺអាស្រ័យទៅលើអ្នកដឹកនាំគ្រប់គ្រងល្អ មានចំណេះដឹងក្នុងការគ្រប់គ្រងបុគ្គលិក និងលទ្ធផលនៃការចុះឈ្មោះសិស្សចូលរៀនកើនឡើងជាលំដាប់។ ការគ្រប់គ្រងដឹកនាំរបស់អង្គភាពមួយអាចទទួលបានជោគជ័យ លុះត្រាតែមានកិច្ចសហការពីថ្នាក់ដឹកនាំជាន់ខ្ពស់ ថ្នាក់ដឹកនាំកណ្តាល លោកគ្រូអ្នកគ្រូ សហគមន៍ អជ្ញាធរដែនដី មាតាបិតាសិស្ស ចូលរួមទាំងអស់គ្នា។

អ្នកសិក្សាស្រាវជ្រាវយល់ស្របតាមការឱ្យនិយមន័យរបស់លោក Tony Bush, (2021) អ្នកដឹកនាំគ្រប់គ្រង គឺជាមនុស្សម្នាក់ដែលធ្វើឱ្យអង្គភាពរបស់ខ្លួនមានភាពល្បីល្បាញ ព្រមទាំងមានទេព្យកោសល្យក្នុងការបណ្តុះបណ្តាលបុគ្គលិកឱ្យមានឆន្ទៈអនុវត្តការងារ។ ម្យ៉ាងទៀតមានប្រជាប្រិយភាពក្នុងការគៀងគរជំនួយអំពីសប្បុរសជន អង្គការ មាតាបិតា សហគមន៍ និង សិស្សានុសិស្សដែលធ្លាប់រៀននៅក្នុងសាលានោះដែលមានលទ្ធភាព ដើម្បីជួយទ្រទ្រង់សាលាឱ្យមានការអភិវឌ្ឍ។ បន្ថែមពីនេះទៅទៀតអ្នកដឹកនាំគ្រប់គ្រង គឺចាំបាច់មិនអាចខ្វះបានគឺសមត្ថភាពក្នុងការដឹកនាំអ្នកក្រោមបង្គាប់ធ្វើតាមគោលការរបស់ខ្លួន ។ ជាមនុស្សដែលមានចំណេះ ជំនាញច្បាស់លាស់ ក្នុងការបង្ហាត់បង្រៀនបុគ្គលិក។ ជាមនុស្សមានសុជីវធម៌ចំពោះខ្លួនឯង និង ដទៃ។ ជាមនុស្សពូកែស្តាប់ និង ចេះគិតពិចារណា ថ្លឹងថ្លែង ល្អ អាក្រក់។ ជាមនុស្សមានសំដីសំដៅទន់ភ្លន់តែម៉ឺងមាត់ ចេះទំនាក់ទំនងល្អជាមួយមនុស្សរាល់គ្នា។ ជាមនុស្សមានឆន្ទៈ

ក្នុងការងារ មានសមត្ថភាពក្នុងការដឹកនាំគ្រប់គ្រង មានសុជីវធម៌ក្នុងការរស់នៅក្នុងសង្គម និងមានសុខភាពល្អដើម្បីដឹកនាំធនធានមនុស្សឆ្ពោះដល់គោលដៅដោយជោគជ័យ។ សុភាសិតមួយពោលថា« **នៅពេលអ្នកក្លាយជាអ្នកដឹកនាំជោគជ័យ អ្នកគឺជាមនុស្សម្នាក់ដែលធ្វើឱ្យអ្នកដទៃទៀតរីកចម្រើនឡើង** » ស្រប នឹងសុភាសិតមួយទៀតបានលើកឡើងថា « **អ្នកដឹកនាំធម្មតា គឺនាំមនុស្សទៅកន្លែងដែលមនុស្សចង់ទៅ ប៉ុន្តែអ្នកដឹកនាំអស្ចារ្យ នាំមនុស្សទៅកាន់កន្លែងដែលមនុស្សមិនចង់ទៅ ហើយជំរុញឱ្យចង់ទៅទាល់តែបាន** »

## ២.១.១ សមត្ថភាពអ្នកដឹកនាំគ្រប់គ្រង:

អ្នកដឹកនាំគ្រប់គ្រង គួរមានកម្រិតវប្បធម៌យ៉ាងទាបបំផុតបរិញ្ញាបត្រ ឬ សញ្ញាបត្រសមមូល និងបទពិសោធន៍ការងារយ៉ាងហោចណាស់៥ឆ្នាំឡើងទៅ។ ចំពោះចំណេះដឹងភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន ជាផ្នែកមួយយ៉ាងសំខាន់ដែលអ្នកដឹកនាំគ្រប់គ្រងត្រូវតែមានដើម្បីងាយស្រួលកក្នុងការទំនាក់ទំនងការងាររបស់ខ្លួន។ នាយកសាលាត្រូវមានសមត្ថភាព និងគុណសម្បត្តិជានាយកសាលា ដោយបង្ហាញពីភាពខ្លាំង និងប្រសិទ្ធភាពការងាររបស់ខ្លួនក្នុងការគ្រប់គ្រង និងបំពេញការងារឱ្យអស់ពីសមត្ថភាព។ យកចិត្តទុកដាក់ចំពោះការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនជាប្រចាំ មានក្រមសីលធម៌វិជ្ជាជីវៈ មានវិន័យ និងការប្ដេជ្ញាចំពោះការងាររបស់ខ្លួន។ អ្នកដឹកនាំគ្រប់គ្រង ត្រូវមានសមត្ថភាពក្នុងការគិតពិចារណា វិភាគដោយប្រមូលភស្តុតាង ទិន្នន័យ និងស្នើជាសេរីក្នុងការដោះស្រាយបញ្ហា ព្រមទាំងមានគំនិតថ្មីៗដើម្បីអភិវឌ្ឍសាលា។ នាយកសាលាត្រូវមានសមត្ថភាពក្នុងការគ្រប់គ្រងរដ្ឋបាលសាលាមានការអភិវឌ្ឍកាន់តែប្រសើរឡើងលើគ្រប់ផ្នែក។ នាយកសាលាត្រូវមានសមត្ថភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការរៀននិងបង្រៀន ដោយចេះកែលម្អកម្មវិធីសិក្សា ផ្ដល់អនុសាសន៍ល្អ ដោយជំរុញគ្រូឱ្យមានឆន្ទៈក្នុងការបំពេញការងារបស់ដោយខ្លួនធ្វើយ៉ាងណាឱ្យលទ្ធផលសិក្សារបស់សិស្សល្អជាលំដាប់( ក្រសួងអប់រំ យុវជន និងកីឡា ,២០១៧ )។

សាព័ត៌មាន AMS ២៧.០៧.២០២១ បានចុះផ្សាយអំពីលក្ខណៈល្អទាំង៦ចំណុចរបស់នាយកសាលា។ យើងដឹងហើយថា ការអប់រំប្រកបដោយគុណភាពទាមទារឱ្យមានការចូលរួមពីឪពុកម្ដាយ សហគមន៍ គ្រូបង្រៀន និងសាលារៀនដែលផ្ដោតសំខាន់លើតួនាទីដឹកនាំរបស់នាយកសាលា។ សមត្ថភាពបំពេញការងារ

ប្រកបដោយវិជ្ជាជីវៈរបស់នាយកសាលា ជាចំណែកក្នុងការពង្រឹងការសិក្សា និងការចុះឈ្មោះចូលរៀនរបស់សិស្ស។ នាយកសាលាល្អសំដៅលើអ្នកដឹកនាំល្អ ចូលរួមអភិវឌ្ឍវិស័យអប់រំ និងគ្រប់គ្រងការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយប្រសិទ្ធភាព។ ខាងក្រោមនេះជាលក្ខណៈសម្បត្តិរបស់នាយកសាលាល្អ។

១.បុគ្គលមានចំណេះដឹងខ្ពស់ និងបទពិសោធនការងារៈ នាយកសាលាល្អត្រូវមានកម្រិតវប្បធម៌ទាបបំផុតត្រឹមបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ឬប្រសិទ្ធផលគ្រប់គ្រាន់ និងមានវិញ្ញាបនបត្រវិជ្ជាជីវៈនាយកសាលា។

## ២.១.២ តួនាទីអ្នកដឹកនាំគ្រប់គ្រង

តួនាទីរបស់នាយកសាលា គ្រប់ដណ្តប់លើគ្រប់វិស័យទាំងអស់នៅក្នុងសាលា មានដូចជា ភាពជាអ្នកដឹកនាំ ការវាយតម្លៃគ្រូ វិនិច្ឆ័យសិស្សនិង ការងារជាច្រើនទៀតនៅក្នុងសាលា។ ដើម្បីក្លាយខ្លួនជានាយកសាលាដែលមានប្រសិទ្ធភាពគឺត្រូវការ ការព្យាយាម អំណត់ អត់ធ្មន់ ខិតខំប្រឹងប្រែងចំណាយពេលវេលាច្រើនទៅលើការងារនោះ។ **១.នាយកសាលាមានតួនាទីជាអ្នកនាំមុខគេ** មានគំនិតវិជ្ជមាន មានចំណង់ខ្លាំងចំពោះការងារ មានស្នាដៃនៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់សាលារៀន និងមានភាពស្ងប់ស្ងាត់ក្នុងស្ថានភាពលំបាក។

**២.នាយកសាលាមានតួនាទីក្នុងការត្រួតពិនិត្យវិន័យសិស្សៈ** វាជាផ្នែកមួយយ៉ាងធំក្នុងការធ្វើឱ្យសិស្សមានវិន័យល្អនៅក្នុងសាលា។ ដំបូងលោកនាយកត្រូវ ធ្វើយ៉ាងណាដើម្បីឱ្យលោកគ្រូអ្នកគ្រូ យល់ដឹងអំពីសារៈសំខាន់អំពីវិន័យសិស្ស ដើម្បីឱ្យពួកគាត់ចូលរួម ក្នុងការពិនិត្យតាមដានសិស្ស និងជូនដំណឹងដល់មាតាបិតា ឬអាណាព្យាបាលបានដឹង ដើម្បីឱ្យពួកគាត់ចូលរួម សហការក្នុងការតាមដានកូនរបស់ពួកគាត់។

**៣.នាយកសាលាមានតួនាទីក្នុងការវាយតម្លៃលទ្ធផលបង្រៀនរបស់គ្រូពួកគេ** បន្ទាប់ពីបានការណែនាំរបស់ការិយាល័យនិងមន្ទីរអប់រំ។ សាលាដែលទទួលបានលទ្ធផលសិក្សារបស់សិស្សបានល្អ គឺជាសាលាដែលមានគ្រូបង្រៀនប្រកបដោយសមត្ថភាពខ្ពស់ ហើយដំណើរការក្នុងការវាយតម្លៃគ្រូ ត្រូវធ្វើឡើងដោយយុត្តិធម៌ និងតម្លាភាព ត្រូវកត់សំគាល់ចំណុចល្អ និង ចំណុចខ្វះខាតដើម្បីឱ្យពួកគាត់បានកែលម្អ។ ៤.

**នាយកសាលាមានតួនាទីអភិវឌ្ឍកម្មវិធីសិក្សា** ធ្វើយ៉ាងណាឱ្យសិស្សចាប់អារម្មណ៍ចង់ចេះ ចង់ដឹង ចង់អាន និង ចង់មកសិក្សានៅក្នុងសាលា។ ការបង្កើតកម្មវិធីសិក្សាដែលមានប្រសិទ្ធភាពហើយគ្របដណ្តប់លើគ្រប់វិស័យផ្សេងៗគ្នាគឺជាវិធីមួយធានាបាននូវប្រសិទ្ធភាពក្នុងការសិក្សា នាយកសាលាមើលគំរូពីសាលាដទៃហើយយកមកអនុវត្តនៅសាលារបស់ខ្លួន។ កម្មវិធីនៅក្នុងសាលារបស់អ្នកត្រូវវាយតម្លៃរាល់ឆ្នាំ ហើយត្រូវកែសម្រួលជាចាំបាច់។ ប្រសិនបើកម្មវិធីសិក្សារបស់អ្នកមិនរឹងមាំហើយសិស្សរបស់អ្នកមិនមានការកើនឡើងនោះទេ វាចាំបាច់ត្រូវតែផ្លាស់ប្តូរកម្មវិធីសិក្សាខ្លះទៀតដើម្បីឱ្យមានគុណភាព និងទាក់ទាញការចុះឈ្មោះចូលរៀនរបស់សិស្សក្នុងសាលារបស់អ្នក។ **៥.តួនាទីរបស់នាយកសាលាក្នុងការពិនិត្យឡើងវិញនូវគោលនយោបាយ និងនិតិវិធីថ្មីៗរបស់រាជរដ្ឋាភិបាល និងក្រសួងអប់រំដែលបានដាក់ចេញ៖** នាយកសាលាគឺជានាថាលោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងឪពុកម្តាយដឹងពីគោលនយោបាយ និងនិតិវិធីទាំងនោះហើយនិងបុគ្គលិកនីមួយៗទទួលខុសត្រូវក្នុងការអនុវត្តតាម។ ៦. **នាយកសាលាមានតួនាទីក្នុងការកំណត់កាលវិភាគសិក្សា** សម្រាប់គ្រូនិងសិស្ស ឱ្យស្របតាមកម្មវិធីរបស់ក្រសួងអប់រំ ដោយមានម៉ោងចូល ម៉ោងចេញ និងបន្ថែមសកម្មភាពផ្សេងៗទៀតនៅក្នុងសាលារបស់លោកអ្នក។ **៧.នាយកសាលាមានតួនាទីក្នុងការជ្រើសរើសគ្រូថ្មី** ជាតួនាទីសំខាន់មួយរបស់នាយកសាលាក្នុងការជ្រើសរើសបុគ្គលិកដែលមានឆន្ទៈ សមត្ថភាព និងការទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ខ្លួន។ **៨.នាយកសាលាមានតួនាទីក្នុងការទំនាក់ទំនងជា**មួយមាតាបិតានិង សហគមន៍ ដែលមិនអាចខ្វះបាន។ ប្រសិនបើមាតាបិតាមានទំនុកចិត្តទៅលើនាយកសាលាពួកគាត់ក៏អាចបរិច្ចាគពេលវេលា និងការគ្រាំទ្រជាវិជ្ជមានសម្រាប់សាលារៀនលោកអ្នក( Derrick Meador, 2014 )

គុណសម្បត្តិទាំង៦របស់នាយកសាលាល្អ៖ ១. **បុគ្គលមានចំណេះដឹងខ្ពស់ និងបទពិសោធន៍ការងារ៖** នាយកសាលាល្អត្រូវមានកម្រិតវប្បធម៌ទាបបំផុតត្រឹមបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ឬ វិញ្ញាបនបត្រវិជ្ជាជីវៈនាយកសាលារៀន។ ជាពិសេសចំណេះដឹងមូលដ្ឋាន ចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ភាសាបរទេស និងបទពិសោធន៍ការងារជាគ្រូបង្រៀនយ៉ាងតិចប្រាំឆ្នាំ។

**២.បុគ្គលមានបំណិនត្រិះរិះពិចារណា និងនវានុវត្តន៍:** នាយកសាលាល្អចាំបាច់ត្រូវស្វែងយល់អំពីក្របខណ្ឌគតិយុត្ត តាមរយៈការអភិវឌ្ឍសមត្ថភាព ការពង្រឹងយន្តការ និងគោលការជំរុញប្រសិទ្ធភាពការងារដោយមានការចូលរួមដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវ។ ជាពិសេសនាកយល្អ មានការគិត និងវិភាគដោយប្រមូលភស្តុតាងក្នុងការដោះស្រាយបញ្ហាឱ្យប្រសើរឡើងក្នុងការបំពេញការងារ។ **៣. បុគ្គលភាពជាអ្នកដឹកនាំល្អ:** ត្រូវគ្រប់គ្រងរដ្ឋបាលសាលារៀនឱ្យមានការអភិវឌ្ឍកាន់តែល្អប្រសើរលើគ្រប់ផ្នែក ប្រកបដោយគុណភាព និងប្រសិទ្ធភាព។ លើសពីនេះ ត្រូវអនុវត្តលើការងារបរិស្ថាន ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងហិរញ្ញវត្ថុ និយតភាពការងារ ការត្រួតពិនិត្យវាយតម្លៃ ការផ្តល់សេវា ការគ្រប់គ្រងទិន្នន័យបុគ្គលិក ថ្នាក់រៀន សិស្ស និងការរៀបចំផែនការសកម្មភាពជាដើម។ នាយកល្អត្រូវធ្វើជាគំរូក្នុងការដឹកនាំ និង ការប្រតិបត្តិល្អសម្រាប់ភាគីពាក់ព័ន្ធទាំងអស់។ **៤. បុគ្គលមានសមត្ថភាពគ្រប់គ្រងការរៀននិងបង្រៀន:** នាយកសាលាល្អជំរុញលើកទឹកចិត្តឱ្យស្វែងសិក្សាជាប្រចាំ។ លើសពីនេះរៀបចំក្រុមបច្ចេកទេស និងកិច្ចប្រជុំបច្ចេកទេសឱ្យបានទៀងទាត់ ជំរុញការស្រាវជ្រាវថ្មីៗ ដើម្បីឱ្យការបង្រៀនរបស់គ្រូកាន់តែមានប្រសិទ្ធភាព។ ម្យ៉ាងវិញទៀតចូលរួមពិនិត្យកែលម្អ អភិវឌ្ឍ និងអនុវត្តកម្មវិធីសិក្សា។ នាយកសាលាល្អត្រូវលើកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន បង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀន និងបុគ្គលិកអប់រំទាំងអស់នៅសាលាឱ្យទទួលបានការសិក្សាស្រាវជ្រាវបន្ថែម។ **៥. បុគ្គលគ្រប់គ្រងសាលារៀនផ្សារភ្ជាប់សហគមន៍:** នាយកសាលាល្អបង្កើតទំនាក់ទំនងជិតស្និទ្ធយូរអង្វែងជាមួយសហគមន៍ អាជ្ញាធរ មាតាបិតាសិស្ស និងអ្នកពាក់ព័ន្ធនានាដើម្បីអភិវឌ្ឍសាលារៀន។ លើសពីនេះទៅទៀត ពង្រឹងការគ្រប់គ្រងដឹកនាំដោយបង្ហាញឱ្យឃើញច្បាស់អំពីផែនការការទទួលខុសត្រូវ តម្លាភាព និងមិនប្រកាន់បក្សពួក។ ម្យ៉ាងវិញទៀតនាយកសាលាត្រូវកសាងទំនុកចិត្តដោយខិតខំបង្កើតសមិទ្ធិផល លទ្ធផលសិក្សាល្អ គោរពឆន្ទៈរួម មានការលះបង់ មានចក្ខុវិស័យ បេសកកម្មវចនាសម្ព័ន្ធច្បាស់លាស់។ **៦. បុគ្គលក្រមសីលធម៌វិជ្ជាជីវៈ:** នាយកសាលាល្អត្រូវប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈគ្រូបង្រៀន ពង្រឹងសាមគ្គីភាព គោរពវិន័យការងារ រក្សាសម្ងាត់វិជ្ជាជីវៈ និងមានភាពស្មោះត្រង់។ លើសពីនេះផ្តល់តម្លៃដល់អ្នកសិក្សា មិនរើសអើង មិនប្រើអំពើហិង្សា មានសីលធម៌រស់នៅល្អប្រកបដោយគុណធម៌ យុ

តិធម៌ សុភនិច្ឆ័យ និងការពិគ្រោះយោបល់ផ្អែកលើភស្តុតាងជាក់ស្តែង (សារព័ត៌មានជាតិ និងអន្តរជាតិ AMS, 2021)។

## ២.២ ការចុះឈ្មោះចូលរៀន

នៅក្នុងក្របខណ្ឌសកល និង តំបន់ ការអប់រំ មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស និងជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ក្នុងន័យនេះ តាមគ្រប់រូបភាពទាំងក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងក្រៅផ្លូវការ ជាមគ្គុទេសន៍រួមចំណែកដ៏សំខាន់ក្នុងការធានាឱ្យការសិក្សាមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និង ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ចាប់តាំងពីចុងឆ្នាំ២០១៥ តាមរយៈកិច្ចប្រជុំថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់ការអប់រំ២០៣០ ដែលរៀបចំដោយអង្គការយូណេស្កូ ប្រទេសនីមួយៗ បានរៀបចំពិនិត្យឡើងវិញនិង ធ្វើមូលដ្ឋាននីយកម្មលើគោលនយោបាយ និង ផែនការយុទ្ធសាស្ត្ររបស់ខ្លួន ឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាបន្ន សមធម៌ និង ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ស្ថិតក្នុងបរិបទនេះ ប្រទេសមួយចំនួនក្នុងតំបន់បាន និង កំពុងរៀបចំគោលនយោបាយ និង យុទ្ធសាស្ត្រឆ្លើយតបទៅនឹងការសិក្សាពេញមួយជីវិតនៅកម្រិតផ្សេងៗគ្នា។ នៅកម្ពុជា មាត្រា៦៥ នៃរដ្ឋធម្មនុញ្ញ បានចែងថា « រដ្ឋត្រូវការពារ និង លើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះ បានទៅដល់ប្រជាពលរដ្ឋគ្រប់រូប » មាត្រា៦៦ « រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមត្ថភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ ស្មើគ្នាក្នុងការកសាងជីវិត »។ រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យ ប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងក្លាយជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០ ដែលត្រូវរុញច្រានដោយកម្លាំងពលកម្មដែលមានទាំងចំណេះដឹងបច្ចេកទេសកម្រិតខ្ពស់ និង បំណិនរូបវន្ត ដូចនេះប្រជាពលរដ្ឋត្រូវតែទទួលបានការអប់រំគ្រប់ៗគ្នា (ក្រសួងអប់រំ យុវជន និងកីឡា ,២០១៥)។

កុមារគឺជាពន្លកថ្មីនៃកោសិកាសង្គម ទាមទារឱ្យមានការយកចិត្តទុកដាក់ជាចាំបាច់នៅក្នុងការថែរក្សា និងផ្តល់ការអប់រំដល់កុមារ ដើម្បីឱ្យមានភាពរុងរឿង ទាំងរាងកាយ ប្រាជ្ញា ស្មារតី សតិអារម្មណ៍ និងក្រមសីលធម៌។ ការអប់រំគឺជាសិទ្ធិមូលដ្ឋានដល់ជនគ្រប់រូប ជាពិសេសកុមារ យោងតាមអនុសញ្ញាសិទ្ធិកុមារមាត្រាទី២៨បានចែងថាកុមារមានសិទ្ធិទទួលបានការអប់រំ ហើយរដ្ឋមានការធានាផ្តល់សេវាការអប់រំនៅថ្នាក់បឋមសិក្សា ដោយឥតបង់ថ្លៃ (ក្រសួងអប់រំ យុវជន និងកីឡា ,២០១០)។

ការចុះឈ្មោះចូលរៀនសំដៅទៅលើសិស្សដែលមានអាយុ៣ឆ្នាំ ដល់៥ឆ្នាំ(មត្តេយ្យ)និងសិស្សអាយុ៦ឆ្នាំ ឬ៧០ខែ(បឋម)នាំកូនមកចុះឈ្មោះចូលរៀន នៅតាមគ្រឹះស្ថានសាធារណៈទូទាំងប្រទេស (ក្រសួងអប់រំ យុវជន និងកីឡា, ២០២១ )។

ការចុះឈ្មោះចូលរៀនក្នុងន័យម្យ៉ាងទៀត គឺការចុះឈ្មោះចូលរៀនតាមកម្រិតថ្នាក់ មានន័យថាសិស្សត្រូវមកចុះឈ្មោះចូលរៀនតាមកម្រិតថ្នាក់ដែលខ្លួនបានឡើងថ្នាក់ក្នុងដើមឆ្នាំសិក្សាថ្មី។

ការចុះឈ្មោះចូលរៀនក្នុងន័យមួយទៀតដែល គឺការផ្ទេរការសិក្សាពីសាលាដទៃទៀត ដើម្បីចូលរៀនក្នុងសាលាផ្សេងមួយទៀតដែលសិស្សចង់រៀន។

## ២.៣ ទំនាក់ទំនង

តាមវចនានុក្រម Oxford,(2019) បានឱ្យនិយមន័យទំនាក់ទំនងថាជាការចែកចាយ ឬផ្លាស់ប្តូរព័ត៌មានដោយការនិយាយ ការសរសេរ ឬការប្រើប្រាស់ឧបករណ៍ផ្ទេរផ្សេងៗទៀត ។

មនុស្សដែលមានទេកោសល្យក្នុងការទំនាក់ទំនង ជាមនុស្សដែលត្រូវបានគេចូលចិត្តរាប់អានច្រើន។ យោងតាម Richard Nordquist, (2019) បានឱ្យនិយមន័យទំនាក់ទំនងថា គឺជាដំណើរការនៃការផ្ញើ និងទទួលសារតាមរយៈ មធ្យោបាយពាក្យសំដី រួមទាំងការនិយាយ ឬ ទំនាក់ទំនងផ្ទាល់មាត់។ មនុស្សដែលមានទំនាក់ទំនងល្អ ជាមនុស្សពូកែស្តាប់ ពូកែនិយាយ ពូកែសរសេរ និងពូកែឆ្លើយតបទាំងក្នុង និងក្រៅកន្លែងធ្វើការងារ មិនថាជួបដោយផ្ទាល់ ឬក៏តាមរយៈអេឡិចត្រូនិចទេ។ ការប្រាស្រ័យទាក់ទង គឺគ្រាន់តែជាសកម្មភាពនៃការផ្ទេរព័ត៌មានពីកន្លែងមួយទៅមនុស្ស ឬពីមនុស្សមួយក្រុម ទៅមនុស្សមួយក្រុមផ្សេងទៀត។

ការសិក្សារបស់ Common Sense Media, (2020) បានឱ្យនិយមន័យទំនាក់ទំនងមួយបែបទៀតថា ជាទង្វើនៃការផ្តល់ឱ្យ ការទទួល និងការចែករំលែកព័ត៌មាន។ ម្យ៉ាងវិញទៀតការនិយាយ ការសរសេរ ការស្តាប់ ឬការអាន។ អ្នកប្រាស្រ័យទាក់ទងល្អ ស្តាប់ដោយយកចិត្តទុកដាក់ និយាយឬសរសេរយ៉ាងច្បាស់ និងគោរពយោបល់ផ្សេងៗ។

## ២.៤ ការលើកកម្ពស់ក្នុងការបំពេញការងារ

ការលើកទឹកចិត្ត ជាកត្តាមួយយ៉ាងសំខាន់ដែលអាចជួយឱ្យការអនុវត្តការងាររបស់បុគ្គលិកទទួលបានជោគជ័យ។ ការលើកទឹកចិត្តបានជំរុញឱ្យបុគ្គលិកមានឆន្ទៈបំពេញការងារប្រកបដោយគំនិតផ្តួចផ្តើម យកចិត្តទុកដាក់ និងមានការទទួលខុសត្រូវចំពោះការងារ ដោយហ៊ានលះបង់ខ្ពស់ទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលា ដើម្បីសម្រេចឱ្យបាននូវគោលដៅដែលអង្គភាពកំណត់ (Thmeythemey, 2015)។

តាមរយៈសារព័ត៌កម្ពុជាថ្មីបានសរសេរថា ការលើកទឹកមាន៧ចំណុចៈ

១. បង្កើតបរិយាកាសរីករាយៈ នៅកន្លែងធ្វើការងារ អ្នកគ្រប់គ្រងត្រូវរៀបចំបន្ទប់មួយសម្រាប់បុគ្គលិកសម្រាក និងពត់ខ្លួនប្រាណនឹងបុគ្គលិកមានពេលក្នុងការទំនាក់ទំនងគ្នា និងកាត់បន្ថយភាពតានតឹង និងបង្កើតឱ្យមានបរិយាកាសរីករាយនៅកន្លែងធ្វើការ វាអាចជួយជំរុញប្រសិទ្ធភាពក្នុងការបំពេញការងារកាន់តែរីកចម្រើន។

២. ធ្វើឱ្យបុគ្គលិកមានអារម្មណ៍ថាមានតម្លៃៈ ជាការពិតណាស់ ពេលដែលមនុស្សខិតខំបំពេញការងារ ហើយពេលដឹងថា ពួកគេត្រូវបានកោតសរសើរ វាជាផ្នែកដ៏សំខាន់ក្នុងការធ្វើឱ្យបុគ្គលិកមានអារម្មណ៍ថាពួកគេជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងអង្គភាពនោះ។

៣. ផ្តល់ឱ្យបុគ្គលិកនូវទំនួលខុសត្រូវៈ ការផ្តល់ការទទួលខុសត្រូវឱ្យមនុស្សបន្តិចម្តងៗ គឺធ្វើឱ្យពួកគេកាន់តែមានទំនុកចិត្តទៅលើសមត្ថភាពរបស់ខ្លួន ដែលនឹងជួយឱ្យពួកគេចូលរួមសកម្មភាពការងារកាន់តែល្អ។ យ៉ាងណាមិញប្រសិនបើអ្នកគ្រប់គ្រងមានអារម្មណ៍ល្អចំពោះអ្វីដែលពួកគេកំពុងធ្វើ ពួកគេនឹងធ្វើបានល្អជាងមុន និងមានលទ្ធផលច្រើនជាមុន។

៤. រក្សាតម្លាភាពៈ ការរក្សាការប្រាស្រ័យទាក់ទងដោយបើកចំហគឺមានសារៈសំខាន់ណាស់សម្រាប់ស្ថាប័ននីមួយៗ ព្រោះវាជួយឱ្យបុគ្គលិកមានអារម្មណ៍ថាខ្លួនមានតម្លៃគ្រប់គ្រាន់នៅក្នុងស្ថាប័នការងារនោះ។ អ្នកគ្រប់គ្រងគួរនិយាយត្រង់ៗ ជាមួយបុគ្គលិក និងជូនដំណឹងដល់ពួកគេអំពីបញ្ហាណាមួយដែលស្ថាប័នកំពុងតែប្រឈមមុខ។ វិធីនេះនឹងពង្រឹងផ្នែកអារម្មណ៍របស់បុគ្គលិកថាពួកគេសំខាន់។

៥. លើកទឹកចិត្តការងារៈ អ្នកដឹកនាំមិនបាច់តម្លើងប្រាក់ខែឱ្យបុគ្គលិកណាម្នាក់ ហៅថាការលើកទឹកចិត្តនោះទេ។ អ្នកគ្រប់គ្រងគ្រាន់តែធ្វើការលើកទឹកចិត្តជាប្រាក់រង្វាន់ខ្លះសម្រាប់ការសម្រេចបានគោលដៅណាមួយ ឬ ជាលិខិតសរសើរ ការញ៉ាំអាហារថ្ងៃត្រង់ ឬជាអ្វីដែលសាមញ្ញៗ។ ទាំងនេះជាវិធីល្អដែលធ្វើឱ្យបុគ្គលិកមានអារម្មណ៍កក់ក្តៅ ព្រមទាំងខិតខំធ្វើការកាន់តែខ្លាំង។

៦. ស្តាប់តម្រូវការរបស់បុគ្គលិកៈ ក្នុងនាមជាអ្នកដឹកនាំគ្រប់គ្រងត្រូវប្រាកដថាតម្រូវការបុគ្គលិកត្រូវបានដោះស្រាយដោយផ្តល់ការវាយតម្លៃជាប្រចាំ និងទៀងទាត់។ ព្យាយាមធ្វើកម្រងសំណួរខ្លីៗដើម្បីស្វែងយល់ថា តើបុគ្គលិកពេញចិត្តនឹងតួនាទីរបស់ពួកគេដែលឬទេ?ប្រសិនបើបានដឹងថា មានបុគ្គលិកណាម្នាក់កំពុងនឹងមានតម្រូវការខ្លាំង អ្នកគ្រប់គ្រងត្រូវប្រាកដថា អាចធ្វើអ្វីមួយដើម្បីជួយពួកគេ។វិធីនេះអ្នកនឹងអាចកំណត់បញ្ហាបានយ៉ាងឆាប់រហ័ស និងផ្តល់ដំណោះស្រាយសមស្របសម្រាប់បុគ្គលិក។ ទោះបីជាបញ្ហាមិនអាចត្រូវបានដោះស្រាយភ្លាមៗក៏ដោយ ក៏បុគ្គលិកនៅតែពេញចិត្តក្នុងការដែលដឹងថា មេកើយរបស់ខ្លួនកំពុងស្តាប់នូវបញ្ហារបស់ពួកគេ។

៧. បញ្ច្រាបចូលជាមួយបុគ្គលិកៈ ប្រសិនបើចង់ឱ្យបុគ្គលិកធ្វើការឱ្យអស់ពីសមត្ថភាព អ្នកគ្រប់គ្រងត្រូវប្រើវិធីដោះស្រាយដោយផ្ទាល់។ ចំណាយពេលប្រាស្រ័យទាក់ទងជាមួយបុគ្គលិកឱ្យបានទៀងទាត់ ដើម្បីយល់ពីអ្វីដែលពួកគេបានធ្វើ និងផ្តល់ជំនួយនៅពេលណាដែលអាចធ្វើបាន(Cambodia News , 2020)។

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី « **ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ** » គឺប្រើប្រាស់វីធីសាស្ត្របរិមាណវិស័យ ដើម្បីសិក្សាស្វែងយល់ ពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ និងការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ។ វិធីសាស្ត្របរិមាណវិស័យ គឺទទួលបានតម្លៃមធ្យមភាគពិន្ទុ ពីកម្រងសំណួរ។

## ៣.១ គម្រោងស្រាវជ្រាវ (Research Design)

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ «**ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ**» ប្រើប្រាស់តែមួយវិធីសាស្ត្រ គឺវិធីសាស្ត្របរិមាណវិស័យ

**១ វិធីសាស្ត្របរិមាណវិស័យ** (Quantitative Research Design) អ្នកសិក្សាស្រាវជ្រាវ គឺប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យពី គ្រូបង្រៀន នាយក និងគណៈគ្រប់គ្រងសាលារៀន។ ការរៀបចំកម្រងសំណួរចែកចេញជាផ្នែក: ១. ព័ត៌មានទូទៅនិងគុណវុឌ្ឍ ២.ភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលា ៣. ការអនុវត្តការងារពាក់ព័ន្ធការចុះឈ្មោះចូលរៀនរបស់សិស្ស ៤. ការលើកកម្ពស់បរិយាកាសការងាររបស់គ្រូបង្រៀននៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ។

តារាង ៣.១គម្រោងស្រាវជ្រាវរៀបរាប់ពីវិធីសាស្ត្រតាមបែបបរិមាណវិស័យ

| គោលបំណង | ឧបករណ៍ស្រាវជ្រាវ | សំណាកគំរូ | ការវិភាគទិន្នន័យ |
|---|---|---|---|

| | | | |
|---|---|---|---|
| អ្នកដឹកនាំគ្រប់គ្រងទៅនឹងការចុះឈ្មោះចូលរៀន។ | បរិមាណវិស័យៈប្រើប្រាស់កម្រងសំណួរ (Questionnaires) | -គណៈគ្រប់គ្រងសាលាចំនួន ១៥ នាក់<br>-គ្រូបង្រៀនចំនួន ១៣៦ នាក់ | -កម្រិតចង្អុលបង្ហាញពីទាបបំផុត (១) និងខ្ពស់បំផុត (៥)<br>-ភាគរយ (%) គម្លាតមធ្យម (Mean)<br>គម្លាតស្តង់ដា (Standard Deviation) |
| លើកកម្ពស់បរិយាកាសការងាររបស់គ្រូ | បរិមាណវិស័យៈប្រើប្រាស់កម្រងសំណួរ (Questionnaires) | -គណៈគ្រប់គ្រងសាលាចំនួន ១៥នាក់<br>-គ្រូបង្រៀនកម្រិតបឋមសិក្សា១៣៦នាក់ | -កម្រិតចង្អុលបង្ហាញពីទាបបំផុត (១) និងខ្ពស់បំផុត (៥)<br>ភាគរយ(%)គម្លាតមធ្យម (Mean)<br>គម្លាតស្តង់ដា (Standard Deviation) |

### ៣.១.១ ការសិក្សាស្រាវជ្រាវតាមបរិមាណវិស័យៈ

**៣.១.១.១ ទំហំសំណាក និងការធ្វើសំណាកៈ** (Sample Size and Sampling Technique)

ការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ គឺរៀបចំកម្រងសំណួរលើក្រដាស និងទៅតាមពេលវេលាដែលបានកំណត់ជាមួយសាលាគោលដៅនីមួយៗ ហើយគ្រប់សំណាកទាំងអស់គឺមានសំណាកតិចតួចដែលមិនបានផ្តល់ឱ្យ និងបំពេញមិនគ្រប់សំណួរ។ ម្យ៉ាងវិញទៀតការសិក្សាស្រាវជ្រាវនេះគឺទទួលបានសំណាកសរុបចំនួន១៤១នាក់ ក្នុងនោះដែលយើងចែកចេញជាពីរផ្នែកគឺមួយផ្នែកសម្រាប់គណៈគ្រប់គ្រងសាលា និងមួយផ្នែកទៀតសម្រាប់គ្រូបង្រៀននៅកម្រិតបឋមសិក្សាដែលស្ថិតនៅក្នុងរាជធានីភ្នំពេញ។

គណៈគ្រប់គ្រងចំនួន១៤នាក់ និងគ្រូបង្រៀនចំនួន១២៧នាក់ បានចូលរួមផ្តល់ទិន្នន័យតាមរយៈកម្រងសំណួរដែលបានផ្តល់ជូនសម្រាប់ការប្រមូលទិន្នន័យ។

តារាង ៣.២ ចំនួនសំណាកនៃការចុះប្រមូលទិន្នន័យ

| ល.រ | ឈ្មោះបឋមសិក្សា | គណៈគ្រប់គ្រង | | គ្រូបង្រៀនបឋម | |
|---|---|---|---|---|---|
| | | ចំនួនសំណាកសរុប | ចំនួនសំណាកទទួលបានសរុប | ចំនួនសំណាកសរុប | ចំនួនសំណាកទទួលបានសរុប |
| ១ | ភ្នំដូនពេញ | ៣ | ៣ | ២០ | ១៩ |
| ២ | អនុវត្ត | ៣ | ៣ | ១៤ | ១០ |
| ៣ | ប្រាំងចំរេះ | ៣ | ២ | ២៩ | ២៩ |
| ៤ | ចំរើនរដ្ឋ | ១ | ១ | ១៧ | ១២ |
| ៥ | ហ.ស.ចាក់អង្រែ | ៣ | ៣ | ៣៥ | ៣៥ |
| ៦ | ចាក់អង្រែភូមិ៣ | ២ | ២ | ២៣ | ២២ |
| **សរុប** | | **១៥** | **១៤** | **១៣៦** | **១២៧** |

### ៣.១.១.២ ឧបករណ៍សម្រាប់ការស្រាវជ្រាវ: ( Research Instrument )

ទិន្នន័យជាបរិមាណវិស័យ គឺប្រើប្រាស់កម្រងសំណួរសម្រាប់ការប្រមូលទិន្នន័យទៅតាមក្រុមគោលដៅនៅកម្រិតសាលាបឋមសិក្សានៅក្នុងរាជធានីភ្នំពេញ តាមចំនួនសំណាកជាក់លាក់ដើម្បីយកមកធ្វើការវិភាគ។ កម្រងសំណួរត្រូវបានរៀបចំឡើង ទៅតាមទ្រឹស្តីអ្នកដឹកនាំគ្រប់គ្រងនឹងការចុះឈ្មោះចូលរៀននៅបឋមសិក្សា និងការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀន ។ ក្រោយពីបានសិក្សាទៅលើទ្រឹស្តី និង បទដ្ឋានគតិយុតមួយចំនួនរបស់ក្រសួងអប់រំយុវជន និងកីឡា រាជធានីភ្នំពេញ លើការដឹកនាំគ្រប់គ្រងសាលារៀននឹងការប្រមូលសិស្សឱ្យចុះឈ្មោះចូលរៀន និងការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀន ។ អ្នកសិក្សាស្រាវជ្រាវបានសំយោគយកខ្លឹមសារចំនួនបីចំណុច គឺ ១.ភាព

ជាអ្នកគ្រប់គ្រងដឹកនាំរបស់នាយកសាលានៅកម្រិតបឋមសិក្សា។ ២.ការអនុវត្តការងារពាក់ព័ន្ធការចុះឈ្មោះចូលរៀនរបស់សិស្ស។ ៣.លើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀននៅបឋមសិក្សា។

កម្រងសំណួរសម្រាប់ការប្រមូលទិន្នន័យ បានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ«ក»

### ៣.១.១.៣ កម្រិតចង្អុលបង្ហាញៈ

កម្រិតចង្អុលបង្ហាញ គឺប្រើប្រាស់ក្នុងទម្រង់សំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតបក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញបានបង្ហាញតាមរយៈការគូសដោយផ្ទាល់នៅលើក្រដាសកម្រងសំណួរ របស់ប្រធានបទសិក្សាស្រាវជ្រាវ។ ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន៥កម្រិត (Likert Scale) ។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បីវាស់វែងសូចនាករ វាយតម្លៃលើកម្រិតនៃការបំពេញការងារក្នុងការប្រមូលសិស្សចុះឈ្មោះចូលរៀន របស់អ្នកដឹកនាំគ្រប់គ្រង។

កម្រិតចង្អុលបង្ហាញរបស់កម្រងសំណួរនីមួយៗ មាន៥កម្រិតទាបបំផុត(១) ទៅខ្ពស់បំផុត(៥)៖

១ គឺ មិនយល់ស្របខ្លាំង

២ គឺ មិនយល់ស្រប់

៣ គឺ យល់ស្របខ្លះ

៤ គឺ យល់ស្រប

៥ គឺ យល់ស្រប់ខ្លាំង

ការបកស្រាយខាងលើ ការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើពិន្ទុមធ្យមភាគនៃសូចនាករនីមួយៗ គឺមានរូបមន្ត Best (1981) ដូចខាងក្រោមៈ

$$\frac{\text{ពិន្ទុខ្ពស់បំផុត} - \text{ពិន្ទុទាបបំផុត}}{\text{លេខរៀងនៃកម្រិត}} = \frac{៥ - ១}{៥} = \frac{៤}{៥} = 0.៨0$$

១.00 - ១.៨0 មានន័យថា មិនយល់ស្របខ្លាំង(Strongly disagree)

១.៨១ - ២.៦០ មានន័យថា មិនយល់ស្រប (Disagree)

២.៦១ - ៣.៤០ មានន័យថា យល់ស្របខ្លះ(Neutral)

៣.៤១ - ៤.២០ មានន័យថា យល់ស្រប(Agree)

៤.២១ - ៥.00 មានន័យថា យល់ស្របខ្លាំង(Strongly agree)

៣.១.១.៤ កម្រងសំណួរ:

កម្រងសំណួររៀបចំឡើងដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវ ដោយសំយោគចូលគ្នារវាងសូចនាករនៃភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះសិស្សចូលរៀននៅកម្រិតបឋមសិក្សា និងការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀន ដើម្បីបង្កើតកម្រងសំណួរ។ កម្រងសំណួរត្រូវបានចែកចេញជាពីរ គឺកម្រងសម្រាប់គ្រូ និង សម្រាប់គណៈគ្រប់គ្រងសាលា។ សម្រាប់ទិន្នន័យដែលទទួលបាន គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។

កម្រងសំណួរសម្រាប់គ្រូបង្រៀន

កម្រងសំណួរសម្រាប់គ្រូ គឺប្រើប្រាស់សម្រាប់ការប្រមូលទិន្នន័យ ពីនាយកឬនាយិកាដែលចែកចេញជាបួនផ្នែក:

**<u>ផ្នែកទី១៖ ព័ត៌មានទូទៅ៖</u>**

ចំពោះផ្នែកទី១នេះអ្នកស្រាវជ្រាវរៀបចំសំណួរទាក់ទងទៅនឹង ឈ្មោះសាលា ភេទ អាយុ មុខតំណែង កម្រិតវប្បធម៌ បទពិសោធន៍ការងារ ភាសាបរទេស និង បច្ចេកវិទ្យា ។

**<u>ផ្នែកទី២៖ ភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលានៅកម្រិតបឋមសិក្សា</u>**

ចំពោះផ្នែកទី២ អ្នកសិក្សាស្រាវជ្រាវបានរៀបចំសំណួរមួយចំនួនដែលទាក់ទងទៅនឹង ក. កិច្ចគ្រាំទ្រការរៀននឹងបង្រៀន ខ. ការងាររដ្ឋបាល គ.ការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ឃ.ការគ្រប់គ្រង បណ្ណាល័យ និង ង. ការលើកទឹកចិត្ត ព្រមទាំងមានសូចនាកររងតូចៗសរុបទាំងអស់៣៧។

កម្រងសំណួរទាំងអស់ទាញពីគំរូភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលា ។ អ្នកសិក្សស្រាវ ជ្រាវ បានស្នើសុំមតិយោបល់បន្ថែមរបស់លោកគ្រូអ្នកគ្រូទៅតាមផ្នែកនីមួយៗ ក្នុងគោលបំណងដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយទៅលើកម្រងសំណួរស្រាវជ្រាវ។

**<u>ផ្នែកទី២៖ ការអនុវត្តការងារពាក់ព័ន្ធការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា</u>**

ចំពោះផ្នែកទី២ មានសូចនាករសំខាន់តែមួយគត់ដែលផ្តោតទៅលើ វិធីសាស្ត្រក្នុងការចុះផ្សព្វផ្សាយព័ត៌មាន ទំនាក់ទំនងល្អជាមួយអាជ្ញាធរ មាតាបិតាសិស្ស និង សហគមន៍។ល។ កម្រងសំណួរទាំងនេះ ប្រើប្រាស់ឧបករណ៍ដើម្បីទាញពីទ្រឹស្តីទំនាក់ទំនងរវាងអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ។

**ផ្នែកទី៣៖ លើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀន**

អ្នកសិក្សាស្រាវជ្រាវរៀបចំសំណួរផ្តោតទៅលើសមាសភាព១គឺៈ សមត្ថភាពក្នុងការគ្រប់គ្រងបុគ្គលិក ដែលបានលើកកម្ពស់បរិយាកាសបំពេញការងារដោយរីករាយ និងដោយពេញចិត្ត។ កម្រងសំណួរនេះប្រើប្រាស់ជាឧបករណ៍ឆ្លុះបញ្ចាំងពីការងាររបស់នាយកសាលាដែលពាក់ព័ន្ធនឹងការលើកកម្ពស់បរិយាកាសបំពេញការងាររបស់បុគ្គលិក ដែលកើតមានឡើងក្នុងពេលអនុវត្តការងារជាក់ស្តែងនៅកម្រិតសាលារៀន។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់លោកគ្រូអ្នកគ្រូ និងគណៈគ្រប់គ្រងបន្ថែមដើម្បីឱ្យការប្រមូលទិន្នន័យនេះកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងៈ

**ផ្នែកទី១៖ព័ត៌មានទូទៅនិងគុណវុឌ្ឍិ**

ចំពោះផ្នែកទី១នេះអ្នកស្រាវជ្រាវរៀបចំសំណួរទាក់ទងទៅនឹង ឈ្មោះសាលា ភេទ អាយុ មុខតំណែង កម្រិតវប្បធម៌ បទពិសោធន៍ការងារ ភាសាបរទេស និង បច្ចេកវិទ្យា ។

**<u>ផ្នែកទី២៖ ភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលានៅកម្រិតបឋមសិក្សា</u>**

ចំពោះផ្នែកទី២ អ្នកសិក្សាស្រាវជ្រាវបានរៀបចំសំណួរមួយចំនួនដែលទាក់ទងទៅនឹង ក. កិច្ចគាំទ្រការរៀននឹងបង្រៀន ខ. ការងាររដ្ឋបាល គ.ការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ឃ.ការគ្រប់គ្រង បណ្ណាល័យ និង ង. ការលើកទឹកចិត្ត ព្រមទាំងមានសូចនាកររងតូចៗសរុបទាំងអស់សរុប៣៧។ កម្រងសំណួរទាំងអស់ទាញបានជាគំរូភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលា។ អ្នកដឹកនាំស្រាវជ្រាវ បានស្នើសុំមតិយោបល់បន្ថែមរបស់លោកគ្រូអ្នកគ្រូទៅតាមផ្នែកនីមួយៗ ក្នុងគោលបំណងដើម្បីឱ្យការចុះប្រមូលទិន្នន័យកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយទៅលើកម្រងសំណួរស្រាវជ្រាវ។

**<u>ផ្នែកទី៣៖ ការអនុវត្តការងារពាក់ព័ន្ធការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា</u>**

ចំពោះផ្នែកទី៣ មានសូចនាករសំខាន់តែមួយគត់ដែលផ្តោតទៅលើ វិធីសាស្ត្រក្នុងការចុះផ្សព្វផ្សាយព័ត៌មាន ទំនាក់ទំនងល្អជាមួយអាជ្ញាធរ មាតាបិតាសិស្ស និង សហគមន៍។ល។ កម្រងសំណួរទាំងនេះ ប្រើប្រាស់ឧបករណ៍ដើម្បីទាញពីទ្រឹស្តីទំនាក់ទំនងរវាងអ្នកដឹកនាំគ្រប់គ្រងទៅ និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ។

**ផ្នែកទី៣៖ លើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀន**

អ្នកសិក្សាស្រាវជ្រាវរៀបចំសំណួរផ្តោតទៅលើសមាសភាព១គឺៈ សមត្ថភាពក្នុងការគ្រប់គ្រងបុគ្គលិក ដែលបានលើកកម្ពស់បរិយាកាសបំពេញការងារដោយភាពរីករាយ និងដោយពេញចិត្ត។ កម្រងសំណួរនេះប្រើប្រាស់ជាឧបករណ៍ឆ្លុះបញ្ចាំងពីការងាររបស់នាយកសាលាដែលពាក់ព័ន្ធនឹងការលើកកម្ពស់បរិយាកាសបំពេញការងាររបស់បុគ្គលិក ដែលកើតមានឡើងក្នុងពេលអនុវត្តការងារជាក់ស្តែងនៅកម្រិតសាលារៀន។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបរបស់លោកគ្រូអ្នកគ្រូ និងគណៈគ្រប់គ្រងបន្ថែមដើម្បីឱ្យការប្រមូលទិន្នន័យនេះកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយ។

៣.១.១.៥ ការវិភាគទិន្នន័យតាមបរិមាណវិស័យ៖(Data Analysis)

កម្រងសំណួរដែលប្រមូលបានពីក្រុមគោលដៅក្នុងការផ្តល់ទិន្នន័យ ត្រូវបានយកមករៀបចំតាមផ្នែករវាងគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន សម្រាប់ជាមូលដ្ឋានក្នុងការវិភាគទិន្នន័យបរិមាណវិស័យ។

ការវិភាគទិន្នន័យដោយផ្តោតសំខាន់ទៅលើៈ ១.ភាគរយ(%)២. មធ្យមភាគពិន្ទុ (Mean) និង ៣. គម្លាតស្តង់ដា(Standard Deviation)។ សំណួរស្រាវជ្រាវ គឺវិភាគទៅលើកម្រងសំណួរដែលផ្តោតសំខាន់ទៅលើសូចនាករគន្លឹះ៣៖ ១.ភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលា ២. ការងារពាក់ព័ន្ធទៅនឹងការចុះឈ្មោះចូលរៀនរបស់សិស្ស ៣.ការលើកកម្ពស់បរិយាកាសក្នុងការបំពេញការងាររបស់គ្រូបង្រៀន។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរដែលមានលក្ខណៈជាពហុជ្រើសរើសទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗ ក្នុងទម្រង់បិទ និងការផ្តល់មតិយោបល់សម្រាប់ស្វែងរកទិន្នន័យជាធាតុចូលបន្ថែម។ អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ Microsoft Excel ដើម្បីសិក្សាវិភាគរយ ពិន្ទុមធ្យមភាគ និងគម្លាតស្តង់ដារ ដើម្បីវិភាគទៅលើ ៖ ១.ភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលា ២. ការងារពាក់ព័ន្ធទៅនឹងការចុះឈ្មោះចូលរៀនរបស់សិស្ស ៣.ការលើកកម្ពស់បរិយាកាសក្នុងការបំពេញការងាររបស់គ្រូបង្រៀន។

## ៣.២ ក្រមសីលធម៌នៃការស្រាវជ្រាវៈ

អ្នកសិក្សាស្រាវជ្រាវបានប្រកាន់ខ្ជាប់នៅគោលការណ៍ និងក្រមសីលធម៌វិជ្ជាជីវៈក្នុងការចុះប្រមូលទិន្នន័យ នៅតាមក្រុមគោលដៅដែលបានកំណត់នៅក្នុងការស្រាវជ្រាវទៅលើប្រធានបទនេះ។ លិខិតឧទ្ទេសនាមសម្រាប់បំពេញបេសកម្មត្រូវបានអនុញ្ញាតដោយវិទ្យាស្ថានជាតិអប់រំ ទៅមន្ទីរអប់រំ និងបានប្រគល់ជូនទៅតាមអង្គភាពដែលពាក់ព័ន្ធ។ ការចុះប្រមូលទិន្នន័យ គឺអ្នកសិក្សាស្រាវជ្រាវបានប្រាប់ពីគោលបំណងច្បាស់លាស់ និងរក្សាការសម្ងាត់នៃការផ្តល់ទិន្នន័យលើកម្រងសំណួរ។ ទិន្នន័យដែលបានផ្តល់តាមបរិមាណវិស័យ គឺក្នុងគោលបំណងប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះតែប៉ុណ្ណោះ។ ការផ្តល់ទិន្នន័យពីក្រុមគោលដៅគឺក្នុងលក្ខខណ្ឌពេញចិត្ត មានការចូលរួមទាំងអស់គ្នាក្នុងការសហការ និងផ្តល់ព័ត៌មានដោយឈរលើភាពពិតប្រាកដ និងបទពិសោធន៍ជាក់ស្តែងទៅលើការងារអប់រំ។

# ជំពូកទី៤៖ លទ្ធផល និងពិភាក្សា

ការបកស្រាយ និងការពិភាក្សាទៅលើទិន្នន័យដែលទទួលបានពីបរិមាណវិស័យ ពីគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន។ ប្រធានបទសិក្សាអំពី « ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ » ត្រូវបានលើកយកមកសំយោគស្របតាមគោលបំណងនៃការសិក្សាស្រាវជ្រាវចំនួនពីរគឺ ១. ដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ។ ២. ស្វែងយល់ពីវិធីសាស្ត្រក្នុងការលើកកម្ពស់បរិយាបកាសបំពេញការងាររបស់គ្រូបង្រៀននៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ។

## ៤.១ ទិន្នន័យព័ត៌មានទូទៅ:

នៅក្នុងផ្នែកនេះ មានបង្ហាញព័ត៌មានទូទៅរបស់គណៈគ្រប់គ្រង លោកគ្រូអ្នកគ្រូ ព័ត៌មានលម្អិតពីកម្រិតថ្នាក់ ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍ការងារ ដូចមានបង្ហាញជូននូវផ្នែកខាងក្រោមនេះ។

៤.១.១ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលារៀនៈ

តាមទិន្នន័យ ទទួលបានពីគណៈគ្រប់គ្រងបង្ហាញថា គណៈគ្រប់គ្រង ដែលមានភេទស្រីចំនួន ៤០% និង គណៈគ្រប់គ្រងដែលមានភេទប្រុស មានចំនួន៦០%។ គណៈគ្រប់គ្រង ដែលមានអាយុពីចន្លោះ២៥-៣០ឆ្នាំ មានចំនួន៦.៦៧% អាយុពីចន្លោះ៣៥-៤០ឆ្នាំ មានចំនួន៦.៦៧% និង លើសពី៤០ឆ្នាំឡើងមានចំនួន៨៦.៦៧% ។ គណៈគ្រប់គ្រងដែលបានបញ្ចប់ថ្នាក់ទី១២មានចំនួន ៣៣.៣៣% ហើយអ្នកមានបរិញ្ញាបត្រមានចំនួន៤៦.៦៧% និង អ្នកមានបរិញ្ញាបត្រជាន់ខ្ពស់មានចំនួន២០%។ គណៈគ្រប់គ្រងមានបទពិសោធន៍ការងារពីចន្លោះ១-៥ឆ្នាំ មានចំនួន៦.៦៧% អ្នកមានបទពិសោធន៍ការងារពីចន្លោះ៦-១០ ឆ្នាំមានចំនួន ៦.៦៧% និង អ្នកមានបទពិសោធន៍ការងារលើសពី១៥ ឆ្នាំមាន ចំនួន ៨៦.៦៧% ។

៤.១.២ ព័ត៌មានទូទៅរបស់គ្រូបង្រៀនៈ

តាមទិន្នន័យដែលទទួលបានពីគ្រូបង្រៀនតាមថ្នាក់នីមួយៗនៅកម្រិតបឋមសិក្សាបានបង្ហាញថា គ្រូថ្នាក់ទី១មានចំនួន ២១.៤៣% គ្រូថ្នាក់ទី២មានចំនួន ១៩.០៥% គ្រូថ្នាក់ទី៣មានចំនួន ១៦.៦៧% គ្រូថ្នាក់ទី៤មានចំនួន ១៥.០៨% គ្រូថ្នាក់ទី៥មានចំនួន ១៣.៤៩% គ្រូថ្នាក់ទី៦មានចំនួន ១៤.២៩%។ គ្រូបង្រៀនចំនួន២.៣៨% មានអាយុចាប់ពី ៣១- ៣៥ គ្រូបង្រៀនចំនួន៨.៧៣% មានអាយុចាប់ពី ៣៦-៤០ គ្រូបង្រៀនចំនួន ៨៨.៨៩% មានអាយុលើពី៤០ ។ គ្រូបង្រៀនបានបញ្ចប់ថ្នាក់ទី១២ ចំនួន ៥៦.៣៥% គ្រូបង្រៀនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រចំនួន ៣០.១៦% គ្រូបង្រៀនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន ៣.៩៧% និងគ្រូកម្រិតមូលដ្ឋាន ៩.៥២%។ គ្រូបង្រៀនអ្នកមានបទពិសោធន៍ការងារពីចន្លោះ១១-១៥ ឆ្នាំមាន ចំនួន៥.៥៦% និងអ្នកមានបទពិសោធន៍លើសពី១៥ឆ្នាំមាន ចំនួន ៩៤.៤៤% ។

## ៤.២ ភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលានៅកម្រិតបឋមសិក្សា

៤.២.១ ទិន្នន័យដែលទទួលបាន

ការដឹកនាំគ្រប់គ្រងសាលារៀន ផ្តល់ជូននាយកសាលា គ្រូបង្រៀន សិស្សានុសិស្ស និងអាណាព្យាបាលចូលរួមក្នុងការគ្រប់គ្រងលើដំណើរការនៃការអប់រំឱ្យបានល្អប្រសើរ និងការទទួលខុសត្រូវដើម្បីមានលទ្ធភាពបង្កើតបាននូវបរិយាកាសសិក្សាប្រកបដោយប្រសិទ្ធភាព។ តារាងទិន្នន័យខាងក្រោមនេះបានបង្ហាញពីមធ្យមភាពសរុបនៃភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលាៈ

តារាង៤.១ ៖ក. កិច្ចគាំទ្រការបង្រៀន និងរៀន

| ល.រ | ក. កិច្ចគាំទ្រការបង្រៀន និងរៀន | គណៈគ្រប់គ្រង | | | គ្រូបង្រៀន | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | សាលាបានផ្តល់សម្ភារៈឧបទេស គាំទ្រដល់ដំណើរការបង្រៀន និងរៀន | 4.53 | 0.52 | ល្អណាស់ | 4.48 | 0.55 | ល្អណាស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | សាលាបានបង្កលទ្ធភាពអោយគ្រូ និងគ្រូផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹងទៅវិញទៅមក | 4.60 | 0.51 | ល្អណាស់ | 4.64 | 0.51 | ល្អណាស់ |
| ៣ | សាលា មានការគាំទ្រដល់គ្រូ សម្រាប់ធ្វើការស្រាវជ្រាវ និងច្នៃប្រឌិត | 4.53 | 0.52 | ល្អណាស់ | 4.52 | 0.62 | ល្អណាស់ |
| ៤ | សាលា បានរៀបចំបុគ្គលិកជំនួយផ្នែកបច្ចេកទេសដល់គ្រូបង្រៀន | 3.87 | 1.41 | ល្អ | 4.21 | 0.77 | ល្អណាស់ |
| ៥ | សាលាមានកាលវិភាគថ្នាក់រៀន និងបំណែងចែកម៉ោងពេលច្បាស់លាស់ | 4.67 | 0.49 | ល្អណាស់ | 4.79 | 0.41 | ល្អណាស់ |
| ៦ | សាលា បានត្រួតពិនិត្យជាប្រចាំលើការអនុវត្តកម្មវិធីសិក្សា | 4.73 | 0.46 | ល្អណាស់ | 4.79 | 0.41 | ល្អណាស់ |
| ៧ | សាលា បានបង្កើតបរិយាកាស ក្នុងការផ្លាស់ចំណេះដឹង និងបទពិសោធន៍ តាមរយៈថ្នាក់និទស្សន៍ | 4.47 | 0.83 | ល្អណាស់ | 4.59 | 0.56 | ល្អណាស់ |
| ៨ | សាលា បានលើកទឹកចិត្តគ្រូឱ្យស្រាវជ្រាវរកវិធីសាស្ត្របង្រៀនថ្មីៗ | 4.47 | 0.64 | ល្អណាស់ | 4.55 | 0.56 | ល្អណាស់ |
| ៩ | សាលា បានត្រួតពិនិត្យវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស | 4.67 | 0.49 | ល្អណាស់ | 4.55 | 0.50 | ល្អណាស់ |
| ១០ | សាលា បានជម្រុញអោយគ្រូបង្រៀនប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនសិស្ស | 4.47 | 0.52 | ល្អណាស់ | 4.59 | 0.57 | ល្អណាស់ |
| **សរុប** | | **4.50** | **0.64** | **ល្អណាស់** | **4.57** | **0.55** | **ល្អណាស់** |

តារាង៤.១ ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **កិច្ចគាំទ្រការបង្រៀន និងរៀន** ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៥០)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ "សាលា បានត្រួតពិនិត្យជាប្រចាំលើការអនុវត្តកម្មវិធីសិក្សា" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៧៣)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "សាលា បានរៀបចំបុគ្គលិកជំនួយផ្នែកបច្ចេកទេសដល់គ្រូបង្រៀន" ក្នុងកម្រិត "ល្អ" (មធ្យមភាពពិន្ទុ=៣.៨៧)។

គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **កិច្ចគាំទ្រការបង្រៀននិងរៀន** ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៥៧)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ " សាលាមានកាលវិភាគថ្នាក់

រៀន និងបំណែងចែកម៉ោងពេលច្បាស់លាស់” និង “សាលា បានត្រួតពិនិត្យជាប្រចាំលើការអនុវត្តកម្មវិធីសិក្សា”ក្នុងកម្រិត “ល្អណាស់” (មធ្យមភាគពិន្ទុ=៤.៧៩)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ “សាលា បានរៀបចំបុគ្គលិកជំនួយផ្នែកបច្ចេកទេសដល់គ្រូបង្រៀន” ក្នុងកម្រិត “ល្អណាស់” (មធ្យមភាគពិន្ទុ=៤.២១)។

តារាង៤.២ ៖ ខ.ការងាររដ្ឋបាល

| ល.រ | ខ. ការងាររដ្ឋបាល | គណៈគ្រប់គ្រង | | | គ្រូបង្រៀន | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | សាលា បានកសាងផែនការការងារប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំ | 4.67 | 0.49 | ល្អណាស់ | 4.74 | 0.44 | ល្អណាស់ |
| ២ | សាលា បានបែងចែកភារកិច្ច និងការទទួលខុសត្រូវដល់បុគ្គលិកអប់រំក្រោមឱវាទ | 4.67 | 0.49 | ល្អណាស់ | 4.73 | 0.48 | ល្អណាស់ |
| ៣ | សាលា បានរៀបចំបរិស្ថាន សោភ័ណភាព អនាម័យ និងសណ្តាប់ធ្នាប់ | 4.53 | 0.52 | ល្អណាស់ | 4.71 | 0.49 | ល្អណាស់ |
| ៤ | សាលា បានរៀបចំ និងដឹកនាំការប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ | 4.67 | 0.49 | ល្អណាស់ | 4.83 | 0.37 | ល្អណាស់ |
| ៥ | សាលា បានធ្វើជាអាជ្ញាកណ្តាលក្នុងការផ្សះផ្សាទំនាស់ក្នុងសាលា | 4.47 | 0.64 | ល្អណាស់ | 4.69 | 0.53 | ល្អណាស់ |
| ៦ | សាលា បានប្រើប្រាស់ធនធានសាលារៀនអស់លទ្ធភាព | 4.40 | 0.63 | ល្អណាស់ | 4.43 | 0.72 | ល្អណាស់ |
| ៧ | សាលា ស្រឡាញ់រាប់អានគ្រូបង្រៀន និងបុគ្គលិកអប់រំស្មើៗគ្នា ដោយមិនមានប្រកាន់បក្សពួក ឬក្រុម | 4.67 | 0.49 | ល្អណាស់ | 4.69 | 0.52 | ល្អណាស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨ | សាល មានរៀបចំការប្រជុំ ស្តីពីការងារពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង | 4.20 | 0.86 | ល្អ | 4.40 | 0.64 | ល្អណាស់ |
| ៩ | សាលា បានបញ្ជូនគ្រូចូលរួមវគ្គបណ្តុះបណ្តាល ទាក់ទងនឹងមុខវិជ្ជាឯកទេស | 4.47 | 0.64 | ល្អណាស់ | 4.31 | 0.71 | ល្អណាស់ |
| **សរុប** | | **4.53** | **0.58** | **ល្អណាស់** | **4.61** | **0.54** | **ល្អណាស់** |

តារាង៤.២ ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការងាររដ្ឋបាល** ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៥៣)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ

"សាលា បានកសាងផែនការការងារប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំ" "សាលា បានបែងចែកភារកិច្ច និងការទទួលខុសត្រូវដល់បុគ្គលិកអប់រំក្រោមឱវាទ" "សាលា បានរៀបចំ និងដឹកនាំការប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ" **និង** " សាលា ស្រឡាញ់រាប់អានគ្រូបង្រៀន និងបុគ្គលិកអប់រំស្មើៗគ្នា ដោយមិនមានប្រកាន់បក្សពួក ឬក្រុម" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៦៧)ស្មើៗគ្នា ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "សាលា មានរៀបចំការប្រជុំ ស្តីពីការងារពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង" ក្នុងកម្រិត "ល្អ" (មធ្យមភាពពិន្ទុ=៤.២០)តែទាបជាងមធ្យមភាគសរុប។

គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការងាររដ្ឋបាល** ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៦១)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ " សាលា បានរៀបចំ និងដឹកនាំការប្រជុំប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ" ក្នុងកម្រិត "ល្អណាស់"(មធ្យមភាគពិន្ទុ=៤.៨៣)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "សាលា បានបញ្ជូនគ្រូចូលរួមវគ្គបណ្តុះបណ្តាល ទាក់ទងនឹងមុខវិជ្ជាឯកទេស" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាពពិន្ទុ=៤.៣១)តែទាបជាងមធ្យមភាគសរុប។

តារាង៤.៣ ៖ គ. ការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ

| ល.រ | គ. ការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ | គណៈគ្រប់គ្រង | | | គ្រូបង្រៀន | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | សាលា បង្កើតទំនាក់ទំនងទ្វេភាគីជាមួយឪពុកម្តាយ សហគមន៍ និងសាលាដទៃ | 4.53 | 0.52 | ល្អណាស់ | 4.60 | 0.55 | ល្អណាស់ |
| ២ | ប្រើប្រាស់បណ្តាញផ្សព្វផ្សាយតាមបច្ចុប្បន្នភាព ដើម្បីពង្រីកទំនាក់ទំនងឆាប់រហ័ស | 4.40 | 0.63 | ល្អណាស់ | 4.45 | 0.63 | ល្អណាស់ |
| ៣ | សាលា បានប្រជុំផ្សព្វផ្សាយអំពីដំណើរការ និងវឌ្ឍនភាពនានានៅក្នុងសាលាដល់បុគ្គលិកអប់រំ និងសិស្សានុសិស្ស | 4.53 | 0.52 | ល្អណាស់ | 4.74 | 0.54 | ល្អណាស់ |
| ៤ | នាយកសាលា ទទួលយកព័ត៌មានត្រឡប់យ៉ាងសកម្ម ពីអ្នកដទៃ | 4.33 | 0.82 | ល្អណាស់ | 4.38 | 0.64 | ល្អណាស់ |
| ៥ | គ្រូទាំងអស់ត្រូវបានចូលរួម ក្នុងការធ្វើការសម្រេចចិត្ត លើការងារពាក់ព័ន្ធ | 4.53 | 0.52 | ល្អណាស់ | 4.63 | 0.59 | ល្អណាស់ |
| **សរុប** | | **4.47** | **0.60** | **ល្អណាស់** | **4.56** | **0.59** | **ល្អណាស់** |

តារាង៤.៣ ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ** ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៤៧)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ " សាលា បង្កើតទំនាក់ទំនងទ្វេភាគីជាមួយឪពុកម្តាយ សហគមន៍ និងសាលាដទៃ" " សាលា បានបែងចែកភារកិច្ច និងការទទួលខុសត្រូវដល់បុគ្គលិកអប់រំក្រោមឱវាទ" "សាលា បានប្រជុំផ្សព្វផ្សាយអំពីដំណើរការ និងវឌ្ឍនភាពនានានៅក្នុងសាលាដល់បុគ្គលិកអប់រំ និងសិស្សានុសិស្ស" និង "គ្រូទាំងអស់ត្រូវបានចូលរួម ក្នុងការធ្វើការសម្រេចចិត្ត លើការងារពាក់ព័ន្ធ" ក្នុង

កម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៥៣)ស្មើៗគ្នា ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "នាយកសាលា ទទួលយកព័ត៌មានត្រឡប់យ៉ាងសកម្ម ពីអ្នកដទៃ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាពពិន្ទុ=៤.៣៣)។

គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ** ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៥៦)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ "សាលាបានប្រជុំផ្សព្វផ្សាយអំពីដំណើរការ និងវឌ្ឍនភាពនានានៅក្នុងសាលាដល់បុគ្គលិកអប់រំ និងសិស្សានុសិស្ស" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៧៤)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "នាយកសាលា ទទួលយកព័ត៌មានត្រឡប់យ៉ាងសកម្ម ពីអ្នកដទៃ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាពពិន្ទុ=៤.៣៨)តែទាបជាងមធ្យមភាគសរុប។។

តារាង៤.៤ ៖ ឃ. ការគ្រប់គ្រងបណ្ណាល័យ

| ល.រ | ឃ. ការគ្រប់គ្រងបណ្ណាល័យ | គណៈគ្រប់គ្រង | | | គ្រូបង្រៀន | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | សាលា បានរៀបចំ និងបង្កើតបណ្ណាល័យដោយបំពាក់នូវសៀវភៅ និង សម្ភារៈសម្បូរក្នុងការអាន និងសិក្សាស្រាវជ្រាវ | 4.53 | 0.52 | ល្អណាស់ | 4.63 | 0.52 | ល្អណាស់ |
| ២ | សាលាមានបណ្ណារក្សប្រចាំការទៀងទាត់ | 4.33 | 1.05 | ល្អណាស់ | 4.40 | 1.08 | ល្អណាស់ |
| ៣ | សាលាមានបណ្ណារក្សដែលបានទទួលការបណ្តុះបណ្តាលលើការងារបណ្ណាល័យ | 3.87 | 1.13 | ល្អ | 4.01 | 1.04 | ល្អ |
| ៤ | សាលាមានរបាយការណ៍ ស្តីពីការចូលប្រើប្រាស់បណ្ណាល័យ | 4.00 | 1.07 | ល្អ | 4.44 | 1.03 | ល្អណាស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | សាលាមានកាលវិភាគសម្រាប់ការប្រើប្រាស់បណ្ណាល័យ | 4.67 | 0.49 | ល្អណាស់ | 4.76 | 0.47 | ល្អណាស់ |
| ៦ | សាលា បានជំរុញអោយមានការចូលប្រើប្រាស់បណ្ណាល័យ តាមរយៈការអាន និងសកម្មភាពសិក្សាផ្សេងៗ | 4.60 | 0.51 | ល្អណាស់ | 4.58 | 0.59 | ល្អណាស់ |
| ៧ | សាលា បានបញ្ជ្រាបការប្រើប្រាស់បច្ចេកវិទ្យាបណ្ណាល័យទំនើប(e-library) | 3.20 | 1.21 | ល្អ | 3.52 | 1.25 | ល្អ |
| **សរុប** | | **4.17** | **0.85** | **ល្អ** | **4.33** | **0.85** | **ល្អណាស់** |

តារាង៤.៤ ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការគ្រប់គ្រងបណ្ណាល័យ** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៤.១៧)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ "សាលាមានកាលវិភាគសម្រាប់ការប្រើប្រាស់បណ្ណាល័យ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៦៧)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "សាលា បានបញ្ជ្រាបការប្រើប្រាស់បច្ចេកវិទ្យាបណ្ណាល័យទំនើប(e-library)" ក្នុងកម្រិត "ល្អ" (មធ្យមភាពពិន្ទុ=៣.២០)តែទាបជាងមធ្យមភាគសរុប។

គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការគ្រប់គ្រងបណ្ណាល័យ** ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៣៣)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ " សាលាមានកាលវិភាគសម្រាប់ការប្រើប្រាស់បណ្ណាល័យ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៧៦)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "សាលា បានបញ្ជ្រាបបការប្រើប្រាស់បច្ចេកវិទ្យាបណ្ណាល័យទំនើប

(e-library) " ក្នុងកម្រិត "ល្អ" (មធ្យមភាពពិន្ទុ=៣.៥៣)តែទាបជាងមធ្យមភាគសរុប។

តារាង៤.៥ ៖ង. ការលើកទឹកចិត្ត

| ល.រ | ង. ការលើកទឹកចិត្ត | គណៈគ្រប់គ្រង | | | គ្រូបង្រៀន | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | សាលាមានការលើកទឹកចិត្តឱ្យអនុវត្តមេរៀនវិទ្យាសាស្ត្រ និងពិសោធន៍ | 3.47 | 1.13 | ល្អ | 3.66 | 1.19 | ល្អ |
| ២ | សាលាទទួលបានរង្វាន់លើកទឹកចិត្ត ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ | 3.47 | 1.13 | ល្អ | 3.46 | 1.20 | ល្អ |
| ៣ | សាលាលើកសរសើរអ្នកដែលបានរៀបចំសម្ភារៈពិសោធន៍ឱ្យមានរបៀប ក្រោយបញ្ចប់ដំណើរការពិសោធន៍នីមួយៗ | 3.60 | 1.06 | ល្អ | 3.60 | 1.18 | ល្អ |
| ៤ | សាលា មានទំនាក់ទំនងល្អ ជាមួយគ្រូបង្រៀន និងបុគ្គលិកក្រោមបង្គាប់ | 4.73 | 0.46 | ល្អណាស់ | 4.88 | 0.36 | ល្អណាស់ |
| ៥ | សាលា លើកទឹកចិត្តសិស្ស ដោយជំរុញបរិបទនៃការសិក្សាដោយខ្លួនឯង | 4.53 | 0.52 | ល្អណាស់ | 4.76 | 0.48 | ល្អណាស់ |
| ៦ | សាលា បានបង្កើតវត្តសិក្ខាសាលាដល់គ្រូតាមមុខវិជ្ជាដែលត្រូវបង្រៀន | 3.47 | 1.25 | ល្អ | 3.74 | 1.20 | ល្អ |
| **សរុប** | | **3.88** | **0.92** | **ល្អ** | **4.02** | **0.94** | **ល្អ** |

តារាង៤.៥ ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការលើកទឹកចិត្ត** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ= ៣.៨៨)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ

"សាលាមានទំនាក់ទំនងល្អ ជាមួយគ្រូបង្រៀន និងបុគ្គលិកក្រោមបង្គាប់" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៧៣) ។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "សាលាមានការលើកទឹកចិត្តឱ្យ

អនុវត្តមេរៀនវិទ្យាសាស្ត្រ និងពិសោធន៍" "សាលាទទួលបានរង្វាន់លើកទឹកចិត្ត ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ" និង "សាលាបានបង្កើតវគ្គសិក្ខាសាលាដល់គ្រូតាមមុខវិជ្ជាដែលត្រូវបង្រៀន" ក្នុងកម្រិត "ល្អ" (មធ្យមភាពពិន្ទុ=៣.៤៧) ស្មើៗគ្នាទាបជាងមធ្យមភាគសរុប។

គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការលើកទឹកចិត្ត** ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.០២)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ "សាលា មានទំនាក់ទំនងល្អ ជាមួយគ្រូបង្រៀន និងបុគ្គលិកក្រោមបង្គាប់" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៨៨)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ "សាលាទទួលបានរង្វាន់លើកទឹកចិត្ត ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ" ក្នុងកម្រិត "ល្អ" (មធ្យមភាពពិន្ទុ=៣.៤៦)តែទាបជាងមធ្យមភាគសរុប។។

តារាងសរុបរួម៤.៦៖ ភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកនៅកម្រិតបឋមសិក្សា

| ល.រ | បរិយាយ | គណៈគ្រប់គ្រង | | | គ្រូបង្រៀន | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | កិច្ចគាំទ្រការបង្រៀន និងរៀន | **4.50** | **0.64** | **ល្អណាស់** | **4.57** | **0.55** | **ល្អណាស់** |
| ២ | ការងាររដ្ឋបាល | 4.53 | 0.58 | ល្អណាស់ | 4.61 | 0.54 | ល្អណាស់ |
| ៣ | ការងារទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ | 4.47 | 0.60 | ល្អណាស់ | 4.56 | 0.59 | ល្អណាស់ |
| ៤ | ការគ្រប់គ្រងបណ្ណាល័យ | 4.17 | 0.85 | ល្អ | 4.33 | 0.85 | ល្អណាស់ |
| ៥ | ការលើកទឹកចិត្ត | 3.88 | 0.92 | ល្អ | 4.02 | 0.94 | ល្អ |
| **សរុប** | | **4.31** | **0.71** | **ល្អណាស់** | **4.41** | **0.69** | **ល្អណាស់** |

តាមតារាងសរុប៤.៦ ទិន្នន័យសរុបដែលទទួលបានពី នាយកសាលា និងគ្រូបង្រៀន អំពីភាពជាអ្នកដឹកនាំនឹងគ្រប់គ្រងរបស់នាយកសាលានៅកម្រិតបឋមសិក្សា ទទួលមធ្យមពិន្ទុ ៤.៣៦ ស្ថិតនៅកម្រិតល្អណាស់។ នៅក្នុងតារាងនោះផងដែល សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ ការងាររដ្ឋបាលក្នុងកម្រិត «ល្អណាស់»(មធ្យមភាពពិន្ទុ=៤.៥៣)។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺៈ ការលើកទឹកចិត្តក្នុងកម្រិត «ល្អ»(មធ្យមភាពពិន្ទុ=៣.៨៨)។

គណៈគ្រប់គ្រង គ្រូបង្រៀន បានយល់ស្របគ្នាលើភាពជាអ្នកដឹកនាំគ្រប់គ្រងសាលា ដែលផ្តោតទៅលើសមាសភាព៥គឺៈ កិច្ចគាំទ្រការរៀន និងបង្រៀន ការងាររដ្ឋបាល ការងារទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការ ការគ្រប់គ្រងបណ្ណាល័យ និងការលើទឹកចិត្ត។ សមត្ថភាពដឹកនាំរបស់នាយកសាលាពិតជាបានប្រែក្លាយសាលាឱ្យមានការពេញនិយមរបស់សិស្សានុសិស្ស ហើយស្របតាមយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងដឹកនាំតាមសាលារៀនផងដែរ។ សមត្ថភាពក្នុងការដឹកនាំគ្រប់គ្រប់ ជាគំរូដ៏ល្អមួយដែលអាចផ្លាស់ប្តូរសាលាទៅជាវិជ្ជមាន ដោយឥរិយាបថអ្នកដឹកនាំគ្រប់គ្រងសាលា ជាតួអង្គគំរូដល់អ្នកទាំងអស់គ្នាក្នុងសាលា។

នាយកបានបំពេញកិច្ចការងារដោយផ្អែកទៅលើសមត្ថភាពពិតប្រាកដក្នុងការដឹកនាំសាលារៀន មានមនសិការវិជ្ជជីវៈក្នុងការទទួលខុសត្រូវលើកិច្ចការងារដែលត្រូវអនុវត្ត ចេះសម្របសម្រួលជាមួយសហគមន៍ក្នុងគោលបំណងធ្វើឱ្យសាលាមានការអភិវឌ្ឍឆាប់រហ័ស។

តាមទិន្នន័យខាងលើដែលទទួលបានពីសមសភាពទាំង៥ នៃភាពជាអ្នកដឹកនាំគ្រប់គ្រង "ការលើទឹកចិត្តបុគ្គលិក" ទទួលបានកម្រិតពិន្ទុទាបជាងគេ ដោយបានមធ្យមពិន្ទុ ៣.៩៥(ក្នុងកម្រិតល្អ) គឺគណៈគ្រប់គ្រងសាលា និង ពីគ្រូបង្រៀន ។ ក្នុងន័យនោះផងដែល នាយកសាលាត្រូវពង្រឹងបន្ថែមទៅលើការលើកទឹកចិត្តបុគ្គលិក ព្រោះមានសំខាន់ខ្លាំងណាស់ អ្នកខ្លះយល់ថាលុយសំខាន់រាល់ពេលនិយាយអំពីការលើទឹកចិត្ត ពេលខ្លះពាក្យសម្តី ការសរសើរ ការជំរុញមានការប្រកួតប្រជែង ការដំឡើងតំណែង ការផ្តល់សេរីភាពឱ្យពួកគេធ្វើការសម្រេចចិត្ត និង អញ្ជើញពួកគេនិងក្រុមគ្រួសារពួកគេឱ្យចូលរួមកម្មវិធីផ្សេងៗក៏ជា

ការលើកទឹកចិត្តផងដែរ។ ដូចនេះការលើកទឹកចិត្តធ្វើឱ្យបុគ្គលិកខិតខំបំពេញការងារអស់ពីកម្លាំងកាយ កម្លាំងចិត្ត ពុះពារគ្រប់ឧបសគ្គ មិនខ្លាចនឿយហត់ (Kohsantepheap, 2020)។

## ៤.៣ ការអនុវត្តការងារពាក់ព័ន្ធការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា

### ៤.៣.១ ទិន្នន័យដែលទទួលបាន

ការងារពាក់ព័ន្ធនឹងការចុះឈ្មោះសិស្សចូលរៀននេះជាតួនាទីយ៉ាងសំខាន់បំផុតរបស់នាយកសាលា ក្នុងការដឹកនាំលោកគ្រូអ្នកគ្រូ ព្រមទាំងសិស្សានុសិស្សចុះផ្សព្វផ្សាយដំណឹងទៅដល់លំនៅដ្ឋានរបស់មាតាបិតាសិស្ស ដើម្បីប្រមូលសិស្សដែលគ្រប់អាយុចូលរៀនបានមកចុះឈ្មោះចូលរៀនឱ្យបាន

គ្រប់ៗគ្នា។ ដើម្បីលើកកម្ពស់គុណភាពអប់រំ និងស្របតាមគោលនយោបាយការសិក្សាពេញមួយជីវិតសិស្សទាំងអស់មានសិទ្ធិទទួលបានការអប់រំ ដោយមិនមានសិស្សណាម្នាក់នៅក្រៅប្រព័ន្ធអប់រំឡើយ។ក្នុងន័យនេះនាយកសាលាគឺមានតួនាទីគៀងគរសិស្ស និងរកវិធីសាស្ត្រយ៉ាងណាដើម្បីទាក់ទាញសិស្សឱ្យចុះឈ្មោះចូលរៀនឱ្យបានគ្រប់គ្រប់គ្នា។

តារាង៤.៧៖ ការអនុវត្តការងារពាក់ព័ន្ធការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា

| ល.រ | ការអនុវត្តការងារពាក់ព័ន្ធការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា | គណៈគ្រប់គ្រង | | | គ្រូបង្រៀន | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | សាលាមានចក្ខុវិស័យ បេសកកម្ម គោលបំណងច្បាស់លាស់ | 4.64 | 0.50 | ល្អណាស់ | 4.51 | 0.58 | ល្អណាស់ |
| ២ | សាលាការរៀបចំផែនការដោយមានការចូលរួមគ្រប់អ្នកពាក់ព័ន្ធ | 4.50 | 0.52 | ល្អណាស់ | 4.50 | 0.56 | ល្អណាស់ |
| ៣ | សាលាមានរចនាសម្ព័ន្ធ និងកិច្ចដំណើរការក្រុមប្រឹក្សាកុមារ/យុវជន | 4.71 | 0.47 | ល្អណាស់ | 4.53 | 0.55 | ល្អណាស់ |
| ៤ | សាលាមានផែនការអភិវឌ្ឍសាលារៀន | 4.71 | 0.47 | ល្អណាស់ | 4.69 | 0.48 | ល្អណាស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | សាលាបានត្រួតពិនិត្យការរៀន និងបង្រៀនជាប្រចាំ | 4.57 | 0.51 | ល្អណាស់ | 4.58 | 0.57 | ល្អណាស់ |
| ៦ | សាលាបានផ្សព្វផ្សាយការចុះឈ្មោះចូលរៀនរបស់សិស្សក្នុងដើមឆ្នាំសិក្សា | 4.71 | 0.47 | ល្អណាស់ | 4.69 | 0.63 | ល្អណាស់ |
| ៧ | សាលាបានដឹកនាំលោកគ្រូអ្នកគ្រូ និងសិស្សចុះផ្សព្វផ្សាយការចុះឈ្មោះចូលរៀន | 4.43 | 0.65 | ល្អណាស់ | 4.55 | 0.79 | ល្អណាស់ |
| ៨ | សាលាមានកិច្ចសហការល្អចំពោះមាតាបិតា ពេលមកចុះឈ្មោះកូនចូលរៀន | 4.79 | 0.43 | ល្អណាស់ | 4.77 | 0.48 | ល្អណាស់ |
| ៩ | ការបំពេញបែបបទចូលរៀនមានភាពងាយស្រួល | 4.71 | 0.47 | ល្អណាស់ | 4.79 | 0.43 | ល្អណាស់ |
| ១០ | សាលាបានផ្តល់ការលើកទឹកចិត្ត ចំពោះសិស្សដែលរៀនពូកែ | 4.86 | 0.36 | ល្អណាស់ | 4.85 | 0.38 | ល្អណាស់ |
| ១១ | សាលាមានរៀបចំកម្មវិធី ជួបពិភាក្សាជាមួយនឹងមាតាបិតាសិស្ស | 4.36 | 0.74 | ល្អណាស់ | 4.35 | 0.69 | ល្អណាស់ |
| ១២ | សាលាមានរៀបចំ កម្មវិធីឧបត្ថម្ភសិស្សក្រីក្រ | 4.86 | 0.36 | ល្អណាស់ | 4.78 | 0.46 | ល្អណាស់ |
| ១៣ | សាលាមានទំនាក់ទំនងល្អជាមួយមាតាបិតាសិស្សក្នុងសហគមន៍ | 4.64 | 0.50 | ល្អណាស់ | 4.63 | 0.55 | ល្អណាស់ |
| ១៤ | សាលាធានាឱ្យមានសម្ភារៈសិក្សា សម្ភារៈឧបទេសឆ្លើយតបការបង្រៀន | 4.21 | 0.80 | ល្អណាស់ | 4.36 | 0.62 | ល្អណាស់ |
| ១៥ | សាលាមានទីធ្លាធំទូលាយ និងបរិស្ថានសិក្សាស្អាត | 4.50 | 0.52 | ល្អណាស់ | 4.48 | 0.53 | ល្អណាស់ |
| ១៦ | សាលាមានការណែនាំសិស្សឱ្យយល់ដឹងពីវិន័យទាំងមុនពេលចូលរៀន និងមុនចេញទៅផ្ទះ | 4.64 | 0.50 | ល្អណាស់ | 4.79 | 0.43 | ល្អណាស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៧ | សាលាបានអនុវត្តកម្មវិធីសិក្សាទាន់ពេល និងបែងចែកមេរៀនច្បាស់លាស់ | 4.79 | 0.43 | ល្អណាស់ | 4.64 | 0.51 | ល្អណាស់ |
| ១៨ | សាលាមានសម្ភារៈ ល្បែងសិក្សា ឆ្លើយតបតម្រូវការសិស្ស | 4.29 | 0.47 | ល្អណាស់ | 4.23 | 0.70 | ល្អណាស់ |
| ១៩ | សាលាមានរង្វាន់ លើកទឹកចិត្តដល់គ្រូបង្រៀនដែលមានស្នាដៃល្អ | 4.36 | 0.63 | ល្អណាស់ | 4.40 | 0.73 | ល្អណាស់ |
| ២០ | សាលាធានាបានសុវត្ថិភាព សន្តិសុខក្នុងការសិក្សារៀនសូត្រ | 4.43 | 0.51 | ល្អណាស់ | 4.58 | 0.53 | ល្អណាស់ |
| ២១ | សាលាបានផ្តល់ព័ត៌មានទាន់ពេលវេលាដល់អាណាព្យាបាល | 4.57 | 0.51 | ល្អណាស់ | 4.58 | 0.54 | ល្អណាស់ |
| ២២ | សាលាបានរៀបចំបញ្ជីកាគណនេយ្យហិរញ្ញវត្ថុ និងបញ្ជីសារពើភ័ណ្ឌ | 4.57 | 0.51 | ល្អណាស់ | 4.64 | 0.66 | ល្អណាស់ |
| ២៣ | សាលាមានកម្មវិធីផ្សារភ្ជាប់បំណិនជីវិតមូលដ្ឋានទៅនឹងតម្រូវការសហគមន៍ | 3.79 | 1.12 | ល្អ | 4.03 | 0.96 | ល្អ |
| ២៤ | សាលាបានបង្កើត និងរក្សាស្នាដៃសិស្សដើម្បីជំរុញឪពុកម្តាយ និងសហគមន៍ឱ្យចូលរួមគាំទ្រ | 3.93 | 1.07 | ល្អ | 4.20 | 0.91 | ល្អ |
| ២៥ | សាលាបានផ្តល់ព័ត៌មានត្រឡប់ជាប្រព័ន្ធដល់សិស្ស គ្រូ មាតាបិតា និងសាលារៀន | 4.50 | 0.52 | ល្អណាស់ | 4.67 | 0.61 | ល្អណាស់ |
| ២៦ | អត្រាសិស្សបោះបង់ការសិក្សាទាប | 4.36 | 0.63 | ល្អណាស់ | 4.55 | 0.56 | ល្អណាស់ |
| ២៧ | សិស្សមានសមត្ថភាពសមនឹងកម្រិតថ្នាក់ | 4.43 | 0.51 | ល្អណាស់ | 4.35 | 0.65 | ល្អណាស់ |
| **សរុប** | | **4.51** | **0.56** | **ល្អណាស់** | **4.54** | **0.60** | **ល្អណាស់** |

តារាង៤.៧ ខាងលើបានបង្ហាញថា គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការអនុវត្តការងារពាក់ព័ន្ធការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា** ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=

៤.៥១)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ “សាលាបានផ្តល់ការលើកទឹកចិត្ត ចំពោះសិស្សដែលរៀនពូកែ” និង “ សាលាមានរៀបចំ កម្មវិធីឧបត្ថម្ភសិស្សក្រីក្រ ” ក្នុងកម្រិត “ល្អណាស់” (មធ្យមភាគពិន្ទុ=៤.៨៦)ស្មើៗគ្នា។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ “សាលាមានកម្មវិធីផ្សារភ្ជាប់បំណិនជីវិតមូលដ្ឋានទៅនឹងតម្រូវការសហគមន៍” ក្នុងកម្រិត “ល្អ” (មធ្យមភាពពិន្ទុ=៣.៧៩)។

គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ការអនុវត្តការងារពាក់ព័ន្ធការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សា** ក្នុងកម្រិត “ល្អណាស់” (មធ្យមភាគពិន្ទុ= ៤.៥១)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺៈ “សាលាបានផ្តល់ការលើកទឹកចិត្ត ចំពោះសិស្សដែលរៀនពូកែ” “សាលាមានរៀបចំ កម្មវិធីឧបត្ថម្ភសិស្សក្រីក្រ” ក្នុងកម្រិត “ល្អណាស់” (មធ្យមភាគពិន្ទុ=៤.៨៦)ស្មើៗគ្នា។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ “សាលាមានកម្មវិធីផ្សារភ្ជាប់បំណិនជីវិតមូលដ្ឋានទៅនឹងតម្រូវការសហគមន៍” ក្នុងកម្រិត “ល្អ” (មធ្យមភាពពិន្ទុ=៣.៧៩) ។

សរុបទៅលើការអនុវត្តការងារពាក់ព័ន្ធការចុះឈ្មោះចូលរៀននៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ នាយកសាលាត្រូវពង្រឹងបន្ថែមទៅលើសូចនាកដែលទាបជាងគេដែលទទួលបានពីគណៈនាយក និងគ្រូទៅលើ សាលាមានកម្មវិធីផ្សារភ្ជាប់បំណិនជីវិតមូលដ្ឋានទៅនឹងតម្រូវការសហគមន៍ ព្រោះអាចឱ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ជំនាញ និងបទពិសោធន៍ផ្នែកបំណិនជីវិតងាយៗដែលទាក់ទងទៅនឹងជីវិតប្រចាំថ្ងៃ នៅក្នុងសង្គមបច្ចុប្បន្ននេះ។ ការរៀនបំណិនជីវិតតាំងពីវ័យក្មេង ផ្សារភ្ជាប់ទៅនឹងតម្រូវការទៅតាមអាទិភាព និងគោលបំណងជួយមនុស្សវ័យក្មេង ឱ្យជៀសផុតពីការប្រឈមនឹងបញ្ហា ដែលបណ្តាលមកពីកង្វះការយល់ដឹង ក្នុងការអនុវត្តអាជីពងាយៗ។

តារាងទី៤.៨៖ តារាងពិភាក្សាលទ្ធផលនៃសំណួរស្រាវជ្រាវទី១

| | ភាពជាអ្នកដឹកនាំ | ការចុះឈ្មោះចូលរៀន | មធ្យមភាគពិន្ទុ | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ទិន្នន័យពីនាយក | ៤.៣១ | ៤.៥១ | ៤.៤១ | ល្អណាស់ |

| | | | | |
|---|---|---|---|---|
| ទិន្នន័យពីគ្រូ | ៤.៤១ | ៤.៥៤ | ៤.៤៧ | ល្អណាស់ |
| មធ្យមភាគសរុប | ៤.៣៦ | ៤.៥២ | ៤.៤៤ | មានទំនាក់ទំនង |

ទិន្នន័យដែលទទួលបានពីនាយកសាលា និងគ្រូបង្រៀន បង្ហាញពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញពិតជាមានទំនាក់ទំនងនឹងគ្នាពិតប្រាកដមែន។ ដោយមធ្យមភាគពិន្ទុដែលទទួលបានពីនាយកទៅលើភាពជាអ្នកដឹកនាំគ្រប់គ្រង គឺ ៤.៤១ ក្នុង«កម្រិតល្អណាស់» និង មធ្យមពិន្ទុដែលទទួលបានពីគ្រូ ៤.៤៧ ក្នុង«កម្រិតល្អណាស់»ដូចគ្នា។ មធ្យមភាគសរុបដែលទទួលបានពីនាយក និងគ្រូ ទៅលើទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាទទួលបានមធ្យមពិន្ទុសរុប ៤.៤៤ ទិន្នន័យនេះបង្ហាញថាមានទំនាក់ទំនងរវាងគ្នាពិតប្រាកដមែន។

ដូចនេះសាលាដែលមានសិស្សចុះឈ្មោះចូលរៀនច្រើនវាអាស្រ័យទៅលើនាយកមានសមត្ថភាពដឹកនាំសាលា ចេះលើកទឹកចិត្តគ្រូក្នុងការបំពេញការងារ មានទំនាក់ទំនងល្អជាមួយសហគមន៍ សិស្សានុសិស្សរីករាយ ម្ដាយឪពុកសិស្សមានទំនុកចិត្តចុះឈ្មោះចូលរៀន។

ឆ្លងតាមលទ្ធផលដែលទទួលបានពីកិច្ចពិភាក្សាក្នុងតារាង៤.៨ ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សា៖ លទ្ធផលបង្ហាញគឺល្អណាស់ ទាំងគណៈគ្រប់គ្រង និងគ្រូ។ គណៈគ្រប់គ្រងនៅបឋមសិក្សាត្រូវយកចិត្តទុកដាក់ខ្ពស់លើការចុះឈ្មោះចូលរៀន ពីព្រោះបឋមសិក្សាគឺជាកម្រិតដំបូងនៃថ្នាលបណ្ដុះបណ្ដាលចំណេះដឹង និងបំណិនក្នុងការសិក្សា។ សិស្សចុះឈ្មោះសិក្សា មានចំនួនតិច នាំឱ្យចំនួនសិស្សដែលចូលសិក្សាក៏មានចំនួនតិចដែរ ក្នុងន័យនេះចំនួនពលរដ្ឋដែលទទួលបានអត្រានៃការអប់រំ ក៏មានការកើនឡើង ឬថយចុះទៅតាមនោះដែរ ដែលធ្វើឱ្យមានផលជះដល់គោលដៅនៃការអប់រំបរិយាបន្ន។ ការបំពេញតួនាទីជាអ្នកដឹកត្រឹមត្រូវ មានការទទួលខុសត្រូវខ្ពស់ទៅលើការលើកទឹកចិត្តគ្រូ ដើម្បីឱ្យពួកគាត់រីករាយក្នុងការបំពេញការងារអស់ពីកំលាំងកាយ

កម្លាំងចិត្ត និងអាចទាញបានជាប្រយោជន៍ ដល់ការចុះឈ្មោះចូលរៀនរបស់សិស្សកាន់តែច្រើនឡើងដោយមាតាបិតាមានទំនុកចិត្តទៅលើសមត្ថភាពរបស់គ្រូនៅកម្រិតបឋមសិក្សា។ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី១៖ ទំនាក់ទំនងភាពជាអ្នកដឹកនាំគ្រប់គ្រង និងការចុះឈ្មោះចូលរៀនរបស់សិស្សានុសិស្សនៅកម្រិតបឋមសិក្សាក្នុងរាជធានីភ្នំពេញ នាយកត្រូវពង្រឹងបន្ថែមទៅលើសូចនាករមួយចំនួនខាងក្រោមនេះ ពីព្រោះសូចនាកទាំងនេះទទួលបានលទ្ធផលក្នុងកម្រិតទាបជាងមធ្យមពិន្ទុសរុប ៖

- ការរៀបចំបុគ្គលិកជំនួយផ្នែកបច្ចេកទេសដល់គ្រូបង្រៀន ទទួលមធ្យមពិន្ទុទាំងនាយក និងគ្រូស្មើនឹង ៤.០៤ ស្ថិតក្នុងកម្រិតល្អ មិនទាន់ទទួលបានមធ្យមពិន្ទុល្អណាស់នៅឡើយទេ ដូចនេះ នាយកត្រូវពង្រឹងទៅលើសូចនាករនេះបន្ថែម ពីព្រោះគ្រូបង្រៀនត្រូវមានចំណេះដឹងទូលំទូលាយ មានកម្រិតវប្បធម៌ខ្ពស់ សិក្សាស្រាវជ្រាវបន្ថែមជាប្រចាំ មានចំណេះដឹងផ្នែកចិត្តគរុកោសល្យ ចេះប្រើប្រាស់វិធីសាស្ត្រទំនើប ទាន់សម័យ និងល្បិចក្នុងការបង្រៀនយ៉ាងប៉ិនប្រសប់ ។ បុគ្គលិកជំនួយត្រូវមានបទពិសោធន៍ក្នុងការបង្រៀនយ៉ាងស្ទាត់ជំនាញគោរពតាមគោលដៅអប់រំជាតិ អាចកសាងប្រទេសជាតិឱ្យមានការអភិវឌ្ឍរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័សដូចបណ្តាលប្រទេសក្នុងតំបន់និងសាកលលោក (Amavasi, 2019)។

បន្ថែមពីនេះនាយកត្រូវពង្រឹងទៅលើការជំរុញឱ្យគ្រូបង្រៀនប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនសិស្ស ទទួលបានមធ្យមពិន្ទុ៤.៥២ ស្ថិតក្នុងកម្រិតល្អណាស់ ប៉ុន្តែវានៅទាបជាមធ្យមពិន្ទុសរុបរបស់នាយកនិងគ្រូ។ ពីព្រោះការជំរុញឱ្យគ្រូបង្រៀនប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀននេះ ស្របទៅនឹងផែនការមេក្នុងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍របស់ប្រទេសកម្ពុជាក្នុង ឆ្នាំ២០២០។ វាផ្តោតទៅលើ ធនធានមនុស្ស ការបណ្តុះបណ្តាល និងការលើកម្ពស់អក្ខរកម្មឌីជីថល។ បច្ចេវិទ្យាព័ត៌មាន និងសារគមនាគមន៍ គឺជាកតាលិករចម្បងមួយក្នុងការលើកម្ពស់ការអភិវឌ្ឍធនធានមនុស្សសម្រាប់សេដ្ឋកិច្ចសតវត្សរ៍ទី២១ (ក្រសួងអប់រំ យុវជន និង កីឡា, ២០១៨)។ ម្យ៉ាងវិញទៀតការផ្តល់សម្ភារឧបទេស គាំទ្រដល់ដំណើរការបង្រៀន និងរៀនលទ្ធផលដែលទទួលបានមធ្យមពិន្ទុ៤.៥០ ស្ថិតក្នុងកម្រិតល្អណាស់ ប៉ុន្តែនៅទាបជា

មធ្យមពិន្ទុសរុបរបស់នាយកនិងគ្រូ ដូចនេះនាយកបន្ថែមទៅលើសូចនាករនេះ ពីព្រោះសម្ភារឧបទេសមានសារៈសំខាន់មិនអាចខ្វះបានក្នុងដំណើរការរៀននិងបង្រៀនមានដូចជា សៀវភៅ ក្រដាស ក្តារខៀន រូបសំណាក វត្ថុពិត ឧបករណ៍បញ្ចាំងរូប សោតទស្សន៍(វិទ្យុ ទូរទស្សន៍ ខ្សែភាពយន្ត..........)អាចជំនួយឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាព( សម្ភារឧបទេស និងវិធីសាស្រ្តប្រើប្រាស់, ២០១៩)។

- ការបញ្ជូនគ្រូចូលរួមវគ្គបណ្តុះបណ្តាល ទាក់ទងនឹងមុខវិជ្ជាឯកទេស ដើម្បីឱ្យគ្រូបង្រៀនគ្រប់កម្រិតសិក្សាប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបទៅនឹងការពង្រីកប្រព័ន្ធអប់រំរួមទាំងការពង្រីក

សមត្ថភាពអ្នកគ្រប់គ្រង គ្រូឧទ្ទេស នាយកសាលា និងមន្ត្រីអប់រំសំខាន់ៗផ្សេងទៀត និងដើម្បីផ្សព្វផ្សាយបន្តដល់សិស្សានុសិស្សផងដែរ។ ក្រសួងអប់រំ យុវជន និងកីឡាផ្អែកតាមនិន្នាការនៃការអនុវត្តគន្លងអាជីពនៅប្រទេសអភិវឌ្ឍ ដើម្បីពង្រឹងគុណភាពបុគ្គលិកអប់រំ ជាពិសេសគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន អ្នកឯកទេសអប់រំ និងអ្នកឯកទេសជាន់ខ្ពស់(ក្រសួង អប់រំ យុវជន និងកីឡា, ២០១៩)។ បន្ថែមពីនេះរៀបចំការប្រជុំ ស្តីពីការងារពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង ពីព្រោះការពិសោធន៍នេះគឺជាមូលដ្ឋានគ្រឹះនៃវិទ្យាសាស្រ្ត ដែលជាមធ្យោបាយជាប្រព័ន្ធនៃការរុករកពិភពលោកជុំវិញយើង។ ការបង្រៀននិងរៀនតាមបែបពិសោធន៍ ជាការបង្រៀនបែបទំនើប ហើយវាទាក់ទាញការចាប់អារម្មណ៍របស់សិស្ស ធ្វើឱ្យសិស្សងាយយល់ ងាយចងចាំ ហើយអាចយកទៅប្រើប្រាស់បានក្នុងជីវភាពរបស់ខ្លួន(By Anne Marie Helmenstine,Ph.D. 2001)។ ចំណុចដែលមិនអាចមើលរំលង គឺការប្រើប្រាស់ធនធានសាលារៀនឱ្យអស់លទ្ធភាព។ អ្នកដឹងទេ កុមារគឺជាអ្នកច្នៃប្រឌិតដ៏អស្ចារ្យដែលយើងនឹកស្មានមិនដល់។ កុមារការបង្កើតសម្ភារៈប្រើប្រាស់ផ្សេងៗដោយការស្រមើលស្រមៃរបស់ពួកគេ ដោយប្រើប្រាស់ធនធានដែលមានស្រាប់ក្នុងសាលាឬនៅផ្ទះរបស់ពួកគេ។ បន្ថែមពីនេះនាយកជាអាជ្ញាកណ្តាលក្នុងការផ្សះផ្សាទំនាស់ក្នុងសាលា សំដៅទៅលើសមត្ថភាពនាយកសាលាក្នុងការដោះស្រាយបញ្ហាដោយមានប្រសិទ្ធភាពទាន់ពេលវេលា យុតិធម៌ មិនលម្អៀង និងមិនប្រកាន់បក្សពួកនិយម។

- ដើម្បីឱ្យកាន់តែល្អប្រសើរ នាយកសាលាគួរតែទទួលយកព័ត៌មានត្រឡប់យ៉ាងសកម្ម ពី

អ្នកដទៃ ស្ថិតក្នុងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន រួចយក គិតពិចារណា និងប្រឹក្សាយោបល់ជាមួយអ្នកដែលមានបទពិសោធន៍ច្រើនជាងខ្លួន មុននឹងធ្វើការសម្រេចចិត្ត។លោកនាយកត្រូវមានចិត្តទូលាយ និងហ៊ានទទួលយកការរិះគន់ ដើម្បីស្ថាបនា(Thmeythmey, 2021)។បន្ថែមពីនេះ ការប្រើប្រាស់បណ្ដាញផ្សព្វផ្សាយតាមបច្ចុប្បន្នភាព ដើម្បីពង្រីកទំនាក់ទំនងឆាប់រហ័សជាចំណុចមួយដែលនាយកសាលាមិនគួរមើលរំលង ពីព្រោះភាពជឿនលឿននៃបច្ចេកវិទ្យាទំនើបក្នុងការប្រាស្រ័យទាក់ទងគ្នា ដើម្បីទទួលបានព័ត៌មានទាន់ហេតុការណ៍ ហើយមានភាពងាយស្រួល និងរហ័សទាន់ចិត្ត។ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងលក្ខណៈជាប្រព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្ដល់ព័ត៌មានឱ្យបានទាន់ហេតុការណ៍(ក្រសួង អប់រំ យុវជន និងកីឡា, ២០១៨)។ លើសពីនេះទៅទៀត បានបញ្ជ្រាបការប្រើប្រាស់បច្ចេកវិទ្យាបណ្ណាល័យទំនើប (e-library) ដើម្បីឱ្យបណ្ណារក្សគាត់បានផ្សព្វផ្សាយដល់សិស្សានុសិស្ស ក្នុងការស្វែងរកឯកសារនានា ដោយមិនចំណាយពេលវេលា ងាយស្រួលមើលបានគ្រប់ទីកន្លែង គ្រប់ពេលវេលា កាត់បន្ថយការទិញ និងអាចចែករំលែកដល់មិត្តភក្តិ ដើម្បីពង្រីកចំណេះដឹងបន្ថែម។ បណ្ណាល័យអេឡិចត្រូនិចខ្មែរ ជាកន្លែងតម្កល់ទុកឯកសារនានា ហើយជាសម្បត្តិរបស់ខ្មែរទាំងអស់គ្នាសម្រាប់បម្រើជាប្រយោជន៍សាធារណៈ ដោយមិនគិតថ្លៃ ព្រមទាំងអាចឱ្យសិស្សានុសិស្សបានជួយប្រទេសជាតិ បានមួយភាពផងដែរ(Khmer research, 2019)។ នាយកសាលាគួរពង្រឹងទៅលើវត្តមានសិស្សចូលបានចូលបណ្ណាល័យឱ្យបានទៀងទាន់ និងត្រូវពិនិត្យរបាយការណ៍សិស្សដែលបាន ចូលប្រើប្រាស់បណ្ណាល័យ ដើម្បីឱ្យការចូលប្រើប្រាស់បណ្ណាល័យមានប្រសិទ្ធភាព គុណភាព និងជាទម្លាប់ល្អដល់សិស្សដែលយកពេលទំនេរចូលអានសៀវភៅ ឬសិក្សាស្រាវជ្រាវកិច្ចការដែលគ្រូដាក់ឱ្យ។ ការអាន ជារឿងចាំបាច់មួយដើម្បីទទួលយកចំណេះដឹង និងបទពិសោធន៍ជីវិតពីមនុស្សដែលធ្លាប់ឆ្លងកាត់រឿងរ៉ាវជាច្រើនដើម្បីទទួលបានឧត្តមភាព(បណ្ណាល័យយើង, ២០១៧)។ ចំណុចសំខាន់មួយទៀត បណ្ណារក្សគួរតែទទួលការបណ្ដុះបណ្ដាលលើការងារបណ្ណាល័យ គឺវាពិតជាមានសារៈសំខាន់ណាស់ ពីព្រោះបណ្ណារក្សត្រូវយល់ច្បាស់ក្នុងការអប់រំកុមារគ្រប់រូបឱ្យដឹងពីសារៈសំខាន់ក្នុងការអាន បណ្ដុះទម្លាប់អាន ផ្ដល់ចំណេះដឹងលើការស្វែងរកសៀវភៅ ការថែរក្សាសៀវភៅ ការជួសជុលសៀវភៅ ការខ្ចី និងសងសៀវភៅត្រឡប់មកវិញ។

- ការបង្កើតវគ្គសិក្ខាសាលាដល់គ្រូតាមមុខវិជ្ជាដែលត្រូវបង្រៀន។ សិក្ខាសិលាពិតជាមានសារៈប្រយោជន៍ដល់លោកគ្រូអ្នកគ្រូគ្រប់កម្រិតថ្នាក់។ សិក្ខាសិលាអាចផ្ដល់ចំណេះដឹងថ្មីៗ ទទួលបានព័ត៌មានល្អៗ និងអាចចែករំលែកបទពិសោធន៍ឱ្យគ្នាទៅវិញទៅមកផងដែរ។ នាយកសាលាអាចជំរុញលោកគ្រូអ្នកគ្រូឱ្យចូលរួមវគ្គបណ្ដុះបណ្ដាលរបស់ក្រសួងអប់រំ ដែលតែងរៀបចំឡើងជាបន្តបន្ទាប់ដូចជាសិក្ខាសិលាស្ដីពីការអប់រំ គ្រូ ICT គម្រោង SEIP និងសិក្ខាសិលាផ្សេងៗទៀតដើម្បីទទួលបានចំណេះដឹងថ្មីៗ យកមកអភិវឌ្ឍសាលារៀន។ បន្ថែមពីនេះ នាយកត្រូវលើកសរសើរអ្នកគ្រូលោកគ្រូណាដែលបានរៀបចំសម្ភារៈពិសោធន៍ឱ្យមានរបៀប ក្រោយបញ្ចប់ដំណើរការពិសោធន៍នីមួយៗ។ ការរៀនទុកដាក់ឧបករណ៍ពិសោធន៍បានត្រឹមត្រូវពិតជាមានប្រយោជន៍ខ្លាំងណាស់ វាងាយស្រួលប្រើប្រាប់នៅបង្រៀនម៉ោងក្រោយទៀត មិនមានផលប៉ះពាល់ដល់សុខភាពអ្នកដទៃ មិនបែក ឬខូចខាត ងាយស្រួលរក និងមានទម្លាប់ល្អទាំងគ្រូទាំងសិស្ស។ នាយកគួរលើកសរសើរទាំងគ្រូទាំងសិស្ស ដើម្បីជាគំរូដល់ថ្នាក់ដទៃៗទៀត។

ជាការពិតណាស់នាយកត្រូវតែផ្ដល់ជារង្វាន់លើកទឹកចិត្ត ដល់គ្រូដែលរកឃើញរបៀបពិសោធន៍ថ្មីៗ ជាការលើកទឹកចិត្តជាប័ណ្ណសរសើរ ដើម្បីឱ្យលោកគ្រូអ្នកគ្រូមានទឹកចិត្តរុករកអ្វីដែលថ្មីបន្តទៀត។ នាយកគួរមានការលើកទឹកចិត្តឱ្យអនុវត្តមេរៀនវិទ្យាសាស្ត្រ និងពិសោធន៍ ជាឧបករណ៍សិក្សាមួយដែលអាចប្រើទាក់ចិត្តកុមារ លើកកម្ពស់ចំណេះដឹងកុមារ។ ការធ្វើពិសោធន៍នេះមានតម្លៃពិសេសគួរឱ្យទាក់ទាញកុមារឱ្យចង់សិក្សាស្រាវជ្រាវ ចេះសហការ ធ្វើការងារជាក្រុម និងភាពច្នៃប្រឌិត។ នាយកសាលាគួរតែបង្កើតឱ្យមានការដាក់បង្ហាញស្នាដៃសិស្ស ដើម្បីជំរុញឪពុកម្ដាយ និងសហគមន៍ឱ្យចូលរួមគាំទ្រ និងបង្កើតនៅជំនឿចិត្តដល់មាតាបិតាសិស្ស ពេលបានឃើញ ស្នាដៃរបស់កូនពួកគេត្រូវបានដាក់តាំង វាជាលទ្ធផលនៃការសិក្សារបស់កូនពួកគេ ហើយពួកគេនឹងសប្បាយរីករាយ មានទំនុកចិត្តទៅលើសាលាផងដែរ។ អត្រាសិស្សបោះបង់ការសិក្សា ជាក្ដីបារម្ភធំបំផុត ដូចនេះនាយកសាលាត្រូវយកចិត្តទុកដាក់ រៀបចំផែនការ និងយុទ្ធសាស្ត្រនានាដើម្បីទប់ស្កាត់ការបោះបង់ការសិក្សា។ សិស្សមានសមត្ថភាពសមតាមកម្រិតថ្នាក់ជាក្ដីបារម្ភ កំឡុងឆ្នាំ ២០២០-២០២១ ប្រទេសជាច្រើននៅលើពិភពលោកទទួលរងគ្រោះពីជំងឺCovid-19 ។ សាលាទាំងអស់នៅប្រទេសកម្ពុជាត្រូវបានបិទ សិស្សមិនបានរៀនគ្រប់គ្រាន់ ឥឡូវសាលាបើដំណើរការឡើងវិញមាន

សិស្សខ្លះមានសមត្ថភាពមិនសមនឹងកម្រិតថ្នាក់ ដូចនេះលោកនាយកត្រូវបង្កើតថ្នាក់បំប៉នបន្ថែមចំពោះសិស្សដែលអង្គុយខុសកម្រិតថ្នាក់។ សាលាគួរមានកម្មវិធីផ្សាភ្ជាប់បំណិនជីវិតមូលដ្ឋានទៅនឹងតម្រូវការសហគមន៍ តាមការស្រាវជ្រាវរបស់និស្សិត ហ៊ាន គឹមអេង ឆ្នាំ២០០៨ បានសរសេរថា គ្រូបង្រៀនភាគច្រើនមិនបានប្រើពេលវេលាសម្រាប់បង្រៀនបំណិនឱ្យបានដល់កម្រិតអប្បបរមាដែលបានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍កម្មវិធីសិក្សា។ កត្តាដែលសាលានឹងសហគមន៍ខ្វះទំនាក់ទំនងនឹងគ្នា និងកត្តាគ្រូខ្វះជំនាញជាហេតុធ្វើឱ្យកម្មវិធីបំណិនជីវិតដែលសាលារៀនបានរៀបចំមិនអាចឆ្លើយតបនឹងតម្រូវការរបស់មាតាបិតាសិស្ស ឬសហគមន៍។ ប្រសិនបើសាលាផ្តោតការយកចិត្តទុកដាក់ទៅលើការបង្រៀនបំណិនដល់សិស្សដោយបង្កើនទំនាក់ទំនងជាមួយសហគមន៍ព្រមទាំងបំផុស និងផ្សព្វផ្សាយពីកម្មវិធីបំណិនជីវិតឱ្យបានទូលំទូលាយទៅដល់សហគមន៍ នោះដំណើរការអភិវឌ្ឍបំណិនជីវិតតាមមូលដ្ឋានប្រាកដជាអាចដំណើរការទៅប្រកបដោយប្រសិទ្ធភាព។ សាលាមានរង្វាន់ លើកទឹកចិត្តដល់គ្រូបង្រៀនដែលមានស្នាដៃល្អ ទស្សនៈThorndike, (2010)និយាយថា ការជំរុញទឹកចិត្ត ឬការលើទឹកចិត្ត ធ្វើឱ្យមនុស្សមានចំណង់ មានសេចក្តីពេញចិត្ត ហើយនឹងភាពជោគជ័យ។ ទស្សនៈSkinner, (2014)និយាយថាៈការលើកទឹកចិត្តជាការរឿងសំខាន់ដែលធ្វើឱ្យបុគ្គលិកភាគច្រើនព្យាយាមការតាមការជំរុញចិត្ត។ ទស្សនៈGuthrie, (2002) និយាយថាការលើកទឹកចិត្តជាការចាំបាច់ ដែលធ្វើឱ្យកើតទំនាក់ទំនងរវាងការខិតខំព្យាយាមធ្វើឱ្យកាន់តែមានប្រសិទ្ធភាពឡើង។ សរុបមកវិញការលើកទឹកចិត្តវាពិតជាសំខាន់ណាស់ក្នុងការធ្វើការងារប្រកបដោយប្រសិទ្ធភាពនិងជោគជ័យ។សាលាធានាឱ្យមានសម្ភារៈសិក្សា សម្ភារៈឧបទេសឆ្លើយតបការបង្រៀន វាពិតជាមានសារៈសំខាន់ ក្នុងដំណើរការបង្រៀន អាចទាក់ទាញអារម្មណ៍សិស្សឱ្យចាប់អារម្មណ៍លើមេរៀន សិស្សងាយយល់ ងាយស្រួលបង្រៀន។ តាមរយៈWpe.com បានសរសេរថា សម្ភារៈឧបទេសបង្កើតឱ្យមានការចាប់អារម្មណ៍ខ្លាំងពីសំណាក់អ្នកសិក្សាដោយជំរុញឱ្យសិស្សអាចប្រើវិញ្ញាណបាន២ឬ៣ដូចជាការមើលឃើញ ការស្តាប់ លឺ និងការប៉ះផ្ទាល់។ សម្ភារៈឧបទេស អាចពញ្ញាក់អារម្មណ៍របស់សិស្សអោយចង់ដឹងតទៅទៀត និងអាចដកស្រង់ភាពស្មុគស្មាញក្នុងមេរៀនមកពន្យល់ក្នុងអត្ថន័យសាមញ្ញបានក្បោះក្បាយ។ សាលាមានសម្ភារៈ ល្បែងសិក្សា ឆ្លើយតបតម្រូវការសិស្ស សាលាគួរមាន

សៀវភៅល្បែងសិក្សាសម្រាប់កុមារដែលផលិតដោយអង្គការ Aide et Acton ព្រោះវាជាឯកសារ និងសម ដែលមានសារៈសំខាន់សម្រាប់លោកគ្រូអ្នកគ្រូយកមកអនុវត្តក្នុងពេលបង្រៀនដើម្បីឱ្យមានប្រសិទ្ធភាព(Aide et Acton, 2019)។ សាលាធានាបានសុវត្ថិភាព សន្តិសុខក្នុងការសិក្សារៀនសូត្រ សាលាគួរមានរបងព័ទ្ធជុំវិញ មានទ្វារត្រឹមត្រូវ មានអ្នកយាមកាមត្រឹមត្រូវ ដែលធានាបាននូវសុវត្ថិភាពខ្ពស់សម្រាប់សិស្ស។ម្យ៉ាងវិញទៀត សាលាមានរៀបចំកម្មវិធី ជួបពិភាក្សាជាមួយនឹងមាតាបិតាសិស្សៈ កិច្ចពិភាក្សាជាមួយមាតាបិតាសិស្ស មួយឆ្នាំពីរដងនៅពេលប្រឡងឆមាសរួច ជាការល្អប្រសើរណាស់ ដើម្បីបង្ហាញលទ្ធផលសិក្សារបស់កូនពួកគាត់រយៈពេលមួយឆមាសម្តង។ ដើម្បីបង្ហាញចំណុចខ្លាំង ចំណុចខ្សោយ ចំណុចត្រូវកែលម្អ ចំណុចដែលត្រូវឱ្យមាតាបិតាជួយ និងចំណុចដែលត្រូវឱ្យគ្រូជួយ និងពិភាក្សារកដំណោះស្រាយធ្វើយ៉ាងណាឱ្យការសិក្សារបស់សិស្សបានប្រសើរឡើង។ ជាការលើកម្ពស់ការអប់រំ មាតាបិតាមានជំនឿចិត្តលើសាលា ថាពិតជាមានការយកចិត្តទុដាក់លើកូនរបស់ពួកគេ។

សាលាបានដឹកនាំលោកគ្រូអ្នកគ្រូ និងសិស្សចុះផ្សព្វផ្សាយការចុះឈ្មោះចូលរៀនៈ ជាការពិតណាស់ នាយកមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំសិស្ស គ្រូ និងបុគ្គលិកក្រោមឱវាទចុះផ្សព្វផ្សាយដល់មាតាបិតា ដោយសរសេរពិជាធំៗ និងប្រើគ្រឿងបំពងសម្លេងដើម្បីឱ្យឪពុកម្តាយដែលមានកូនដល់អាយុត្រូវចូលរៀនយកកូនមកចុះឈ្មោះចូលរៀនឱ្យបានគ្រប់ៗគ្នា ដោយមិនមានការបង់ប្រាក់ទេ។

សរុបជារួមក្នុងកិច្ចពិភាក្សាទី១ ភាពជាអ្នកដឹកនាំគ្រប់គ្រងមានទំនាក់ទំនងនឹងការចុះឈ្មោះចូលរៀនរបស់សិស្សានុសិស្សនៅកម្រិតបឋមសិក្សាៈ នាយកសាលាត្រូវពង្រឹងបន្ថែមទៅលើចំណុចខាងលើនេះ ដើម្បីឱ្យការគ្រប់គ្រងដឹកនាំគ្រប់គ្រងរឹតតែមានប្រសិទ្ធភាព និងការចុះឈ្មោះសិស្សចូលៀនកាន់តែល្អប្រសើរ ហើយវាទាញបានជាប្រយោជន៍ដល់កិត្តិយស មុខមាត់របស់អ្នកដឹកនាំគ្រប់គ្រងល្អផងដែរ(ក្រសួងអប់រំ យុវជន និងកីឡា, ២០១០)។

## ៤.៤ លើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀននៅបឋមសិក្សា

### ៤.៤.១ ទិន្នន័យដែលទទួលបាន

ការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀន ជាកាតព្វកិច្ចរបស់នាយកសាលាដែលមិនអាចខ្វះបាន។នាយកត្រូវចេះវាយតម្លៃសម្ថភាពគ្រូ ជំរុញឱ្យគ្រូឱ្យធ្វើស្វ័យសិក្សាស្រាវជ្រាវ ប្រើប្រាស់បច្ចេកវិទ្យា និងជំរុញគ្រូឱ្យធ្វើពិសោធន៍ក្នុងដំណើរការបង្រៀន ដោយលើកទឹកចិត្តគ្រូដែលខិតខំបំពេញការងារ។ នាយកសាលាត្រូវមានសម្ថភាពដឹកនាំបុគ្គលិកឱ្យចេះសហការ ចែករំលែក និងចេះជួរធុរៈគ្នាទៅវិញទៅមក ដោយក្រមសីលធម៌វិជ្ជាជីវៈជាគ្រូបង្រៀន។

តារាង៤.៩ ៖ ការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀននៅបឋមសិក្សា៖

| ល.រ | លើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀននៅបឋមសិក្សា | គណៈគ្រប់គ្រង | | | គ្រូបង្រៀន | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | រៀបចំគ្រូបង្រៀនឱ្យបានគ្រប់គ្រាន់ ស្របតាមនិយាម និងឯកទេស | 4.21 | 1.12 | ល្អណាស់ | 4.26 | 1.05 | ល្អណាស់ |
| ២ | ជំរុញសមត្ថភាពវិជ្ជាជីវៈរបស់គ្រូបង្រៀនលើការងារពិសោធន៍ | 4.29 | 0.73 | ល្អណាស់ | 4.29 | 0.77 | ល្អណាស់ |
| ៣ | លើកទឹកចិត្ត គ្រូបង្រៀន ឱ្យចូលរួមការប្រជុំបច្ចេកទេស | 4.71 | 0.47 | ល្អណាស់ | 4.69 | 0.52 | ល្អណាស់ |
| ៤ | គ្រូបង្រៀន មិនធ្វើកិច្ចតែងការ និងថ្នាក់និទស្សន៍ | 2.64 | 1.69 | ល្អបង្គួរ | 2.41 | 1.58 | មធ្យម |
| ៥ | ជំរុញការប្រើប្រាស់បច្ចេកវិទ្យា ក្នុងដំណើរការបង្រៀនរបស់គ្រូ | 4.36 | 0.50 | ល្អណាស់ | 4.35 | 0.74 | ល្អណាស់ |
| ៦ | ការបង្រៀន និងរៀនរបស់គ្រូ ទាន់កម្មវិធីសិក្សាប្រចាំឆ្នាំ | 4.57 | 0.51 | ល្អណាស់ | 4.50 | 0.68 | ល្អណាស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧ | ផ្ដល់ឱកាសឱ្យគ្រូបង្រៀន ចូលរួមក្នុងវេទិកាពិព័ណ៌វិទ្យាសាស្ត្រ | 4.00 | 0.96 | ល្អ | 3.78 | 1.04 | ល្អ |
| ៨ | ផ្ដល់ឱកាសឱ្យគ្រូបង្រៀន ផលិតសម្ភារៈឧបទេស | 4.64 | 0.50 | ល្អណាស់ | 4.45 | 0.64 | ល្អ ណាស់ |
| ៩ | ការលើកទឹកចិត្តគ្រូបង្រៀន ក្នុងការចូលរួមសិក្សាស្រាវជ្រាវ | 4.57 | 0.65 | ល្អណាស់ | 4.35 | 0.68 | ល្អ ណាស់ |
| ១០ | ការផ្ដល់ធនធានគ្រូបង្រៀន ឱ្យត្រូវតាមឯកទេសបង្រៀន | 3.86 | 1.17 | ល្អ | 4.16 | 1.04 | ល្អ |
| ១១ | លុបបំបាត់ទំនាស់ផលប្រយោជន៍ការងាររបស់គ្រូ កើតមានឡើងនៅក្នុងអង្គភាព | 4.57 | 0.51 | ល្អណាស់ | 4.50 | 0.73 | ល្អ ណាស់ |
| ១២ | ធានាបានកញ្ចប់ថវិកា សម្រាប់អភិវឌ្ឍសមត្ថភាព គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ | 3.86 | 1.17 | ល្អ | 4.13 | 0.91 | ល្អ |
| ១៣ | រៀបចំបរិស្ថានសិក្សាកុមារមេត្រី នៅក្នុងសាលារៀន | 4.57 | 0.51 | ល្អណាស់ | 4.38 | 0.67 | ល្អ ណាស់ |
| ១៤ | បង្កើតមូលនិធិសមធម៌អប់រំ តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន | 4.14 | 0.95 | ល្អ | 3.98 | 0.94 | ល្អ |
| ១៥ | បិទផ្សាយតារាងតម្លាភាពហិរញ្ញវត្ថុ និងសម្ភារៈទ្រព្យសម្បត្តិរដ្ឋ ធានាបានគណនេយ្យភាពសាលារៀន | 4.64 | 0.63 | ល្អណាស់ | 4.45 | 0.86 | ល្អ ណាស់ |
| ១៦ | សាលារៀន ធានាបានសុវត្ថិភាពគ្រូ និងសិស្ស | 4.64 | 0.50 | ល្អណាស់ | 4.59 | 0.59 | ល្អ ណាស់ |
| ១៧ | សាលារៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកបានសមស្រប | 4.71 | 0.47 | ល្អណាស់ | 4.57 | 0.62 | ល្អ ណាស់ |
| ១៨ | សាលាបានប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យាក្នុងដំណើរការគ្រប់គ្រប់សាលារៀន | 4.57 | 0.65 | ល្អណាស់ | 4.38 | 0.70 | ល្អ ណាស់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៩ | សាលាបានរៀបចំរចនាសម្ព័ន្ធ និងបំណែងចែកភារកិច្ចច្បាស់លាស់ | 4.64 | 0.50 | ល្អណាស់ | 4.74 | 0.47 | ល្អណាស់ |
| ២០ | ជំរុញគំនិតច្នៃប្រឌិត និង ការបង្កើតថ្មីដើម្បីឧត្តមភាពការងារ | 4.43 | 0.65 | ល្អណាស់ | 4.31 | 0.75 | ល្អណាស់ |
| ២១ | បង្ហាញលក្ខណៈក្នុងកិច្ចកសាងវប្បធម៌សហការ និងការចូលរួម | 4.29 | 0.73 | ល្អណាស់ | 4.31 | 0.73 | ល្អណាស់ |
| ២២ | លើកទឹកចិត្ត និងចេះធ្វើការងារជាក្រុម ដើម្បីបង្កើតវប្បធម៌ចែករំលែក | 4.57 | 0.51 | ល្អណាស់ | 4.49 | 0.68 | ល្អណាស់ |
| ២៣ | រៀបចំកម្មវិធីបំប៉នវិធីសាស្ត្រ និងផ្តល់ប្រឹក្សាបច្ចេកទេសដល់គ្រូ | 4.36 | 0.74 | ល្អណាស់ | 4.55 | 0.72 | ល្អណាស់ |
| **សរុប** | | **4.34** | **0.73** | **ល្អណាស់** | **4.29** | **0.79** | **ល្អណាស់** |

តារាង៤.៩ ខាងលើបានបង្ហាញថាពីលទ្ធផលនៃសំណួរស្រាវជ្រាវទី២ គឺ **ការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀននៅបឋមសិក្សា** លទ្ធផលដែលទទួលបានពីគណៈគ្រប់គ្រងបានផ្តល់ទិន្នន័យសរុប ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៤.៣៤)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់ជាងគេគឺ "លើកទឹកចិត្ត គ្រូបង្រៀន ឱ្យចូលរួមការប្រជុំបច្ចេកទេស" និង "សាលារៀបចំសេវាគ្រូបង្រៀន និងបុគ្គលិកបានសមស្រប" ក្នុងកម្រិត "ល្អណាស់"(មធ្យមភាគពិន្ទុ=៤.៧១)ស្មើៗគ្នា។ សូចនាករដែលទទួលបានពិន្ទុទាបជាងគេគឺ " គ្រូបង្រៀន មិនធ្វើកិច្ចតែងការ និងថ្នាក់និទស្សន៍" ក្នុងកម្រិត "មធ្យម" (មធ្យមភាពពិន្ទុ=២.៦៤)។

ឆ្លងតាមលទ្ធផលក្នុងតារាង៤.៩ នៃកិច្ចពិភាក្សាសំណួរស្រាវជ្រាវទី២ **ការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀននៅបឋមសិក្សា** គឺជាកាតព្វកិច្ចសំខាន់របស់ស្ថាប័ន ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹង ជំនាញ និងលទ្ធផលបំពេញការងារ ការផ្លាស់ប្តូរនូវអាកប្បកិរិយា ផ្នត់គំនិត និង

ឥរិយាបថ ឱ្យក្លាយខ្លួនជាទទួលខុសត្រូវ ក្នុងកតព្វកិច្ចរបស់ខ្លួន ដោយភាពរីករាយ ពេញចិត្ត កក់ក្ដៅ យល់ថាខ្លួនមានតម្លៃ ប្រឹងប្រែងអស់កម្លាំងកាយចិត្ត ដោយឆន្ទៈ។

ទោះបីជាយ៉ាងណាក៏ដោយ នៅមានសូចនាករមួយចំនួនដែលទាមទារឱ្យនាយកសាលាត្រូវពង្រឹងបន្ថែម ទៅលើក គ្រូបង្រៀន មិនធ្វើកិច្ចតែងការ និង ថ្នាក់និទស្សន៍ ។ ការងាររបស់គ្រូក្រៅពីការបង្រៀន គ្រូត្រូវរៀបចំការងាររដ្ឋបាលមួយចំនួនដូចជាការតុតែងថ្នាក់រៀន សម្ភារៈឧបទ្ទេស និងកិច្ចតែងការបង្រៀន។ល។ ព្រោះវាជាការងារ ជាកាតព្វកិច្ច ជាតួនាទីរបស់គ្រូត្រូវតែធ្វើ។ ក្នុងការអនុវត្តកម្មវិធីបង្រៀនទំនើបតម្រូវឱ្យមានកិច្ចតែងការមួយយ៉ាងល្អិតល្អន់។ គ្រូបង្រៀនពុំមានលទ្ធភាពបង្រៀន ដោយគ្មានការព្រាងទុកនោះទេ។ បើគ្មានការព្រាងទុកនោះការបង្រៀនរបស់យើងនឹងមិនមានភាពច្បាស់លាស់ ចាប់ត្រង់នោះបន្តិចចាប់ត្រង់នេះបន្តិច និងមានភាពរាវែកមិនធ្វើឱ្យសិស្សចាប់អារម្មណ៍ និង មានភាពស៊ីជម្រៅនោះទេ (Khmer search, 2018)។

ការធ្វើថ្នាក់និទស្សន៍មានសារៈសំខាន់ និងគោលបំណងដើម្បីចែករំលែកវិធីសាស្ត្រក្នុងការបង្រៀន និង រៀនដល់លោកគ្រូអ្នកគ្រូ។ នេះជាជំនួយដ៏ប្រសើរសម្រាប់លោកគ្រូអ្នកគ្រូដើម្បីពង្រឹងសមត្ថភាព និង វិធីសាស្ត្រក្នុងការបង្រៀន។ ដើម្បីឆ្លើយតបទៅនឹងការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀននៅបឋមសិក្សា សាលាត្រូវពង្រឹងបន្ថែមទៅលើ គ្រូបង្រៀន មិនធ្វើកិច្ចតែងការ និងថ្នាក់និទស្សន៍ ដើម្បីឱ្យគ្រូមានសមត្ថភាពខ្ពស់ក្នុងការបង្រៀសិស្សប្រកបដោយប្រសិទ្ធភាព និងធ្វើឱ្យការចុះឈ្មោះរបស់សិស្សចូលរៀនមានការកើនឡើង។ ការបង្ហាញលក្ខណៈក្នុងកិច្ចកសាងវប្បធម៌សហការ និងការចូលរួមពិតជាមានសារៈសំខាន់នាពេលបច្ចុប្បន្ននេះ យើងទាំងអស់គ្នាកំពុងរស់នៅក្នុងសង្គមដែលពោរពេញទៅដោយការប្រកួតប្រជែង។ ជាពិសេសនោះបើនិយាយពីទីផ្សារការងារ មិនថាវិស័យណាមួយទេ យើងឃើញថាមានការប្រកួតប្រជែងសមត្ថភាពគ្នាយ៉ាងខ្លាំង។ បុគ្គលគ្រប់រូបសុទ្ធតែមានសមត្ថភាពរបស់ខ្លួលរៀងៗខ្លួន ប៉ុន្តែដើម្បីសម្រេចបានភាពជោគជ័យធំ បុគ្គលតែម្នាក់មិនអាចសម្រេចបានទេ។ ផ្ទុយទៅវិញដើម្បីសម្រេចការងារធំមួយបានល្អប្រសើរ គឺត្រូវពឹងលើការងារជាក្រុម សហការ និងសាមគ្គីគ្នា ទើបបានជោគជ័យ។ ការ

បង្កើតមូលនិធិសមធម៌អប់រំ តាមរយៈភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន សាលារៀនគួររួបរួមគ្នាបង្កើតមូលនិធិសមធម៌ ដើម្បីបង្ហាញពីការចេះការសហការគ្នា ចេះជួយគ្នាទៅវិញទៅមក ពេលបុគ្គលិកណាមួយជួបបញ្ហា នេះជាការរួមចំណែកដោះស្រាយបញ្ហាឱ្យបុគ្គលិកផងដែរ។ គ្រូបង្រៀន មិនធ្វើកិច្ចតែងការ និងថ្នាក់និទស្សន៍ បើតាមក្របខណ្ឌវិជ្ជាជីវៈជាគ្រូបង្រៀន គ្រូត្រូវមានកិច្ចតែការបង្រៀន វាដូចជាអាវុធសម្រាប់ទៅច្បាំងអញ្ចឹងដែរ។ ការធ្វើថ្នាក់និទស្សន៍ គឺការផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក ហើយស្របតាមកម្មវិធីរបស់ក្រសួងអប់រំ ដើម្បីលើកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនឱ្យមានគុណភាពល្អប្រសើរ។ការជំរុញសមត្ថភាពវិជ្ជាជីវៈរបស់គ្រូបង្រៀនលើការងារពិសោធន៍ពិតជាល្អ ព្រោះការបង្រៀនមានពិសោធន៍ជាក់ស្តែង បង្កើតឱ្យមានការចាប់អារម្មណ៍ខ្លាំងពីសំណាក់អ្នកសិក្សា អាចជំរុញឱ្យសិស្សប្រើញាណពីរ ឬបីដូចជាមើល ស្តាប់ លឺ និងប៉ះ វាអាចពញ្ញាក់អារម្មណ៍របស់សិស្សឱ្យចង់ដឹងតទៅទៀត ហើយអាចដកស្រង់ភាពស្មុគស្មាញក្នុងមេរៀនមកពន្យល់ក្នុងអត្ថន័យសាមញ្ញ បានក្បោះក្បាយ។

សរុបជារួមក្នុងកិច្ចពិភាក្សាទៅលើសំណួរស្រាវជ្រាវទី២ ការលើកកម្ពស់បរិយាកាសបំពេញការងាររបស់គ្រូបង្រៀននៅកម្រិតបឋមសិក្សា ដើម្បីឱ្យកាន់តែប្រសើរឡើងលោកនាយកត្រូវពង្រឹងទៅលើសូចនាករខាងលើមួយចំនួនបន្ថែមទៀតដើម្បីឱ្យបរិយាកាសបំពេញការងាររបស់គ្រូកាន់តែល្អប្រសើរជាងនេះ និងជួយជំរុញដល់ការចុះឈ្មោះចូលរៀនរបស់សិស្សនៅកម្រិតបឋមសិក្សាកាន់តែមានការកើនឡើង ដែលជាប្រយោជន៍ដល់សង្គមជាតិរបស់យើង។

